# មាតិកា

ឆ្ពោះទៅមុខ ..... 2
អាយឆា៖ អ្វីដែលអ្នកត្រូវដឹង ..... 3
សេចក្តីផ្តើម ..... 3
អាយឆា ..... 9
សំនួរដែលសួរជាញឹកញាប់ ..... 19
តំណាងអាយឆា ២០១៦-២០១៨ ..... 21
តំណាងអាយឆា ២០១៣-២០១៥ ..... 31
តំណាងអាយឆា ២០០៩-២០១២ ..... 35
លក្ខន្តិក៍នៃគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ..... 40



# ឆ្ពោះទៅមុខ

អាស៊ានសម្រេចបាននូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយជាមួយនឹងការបង្កើតគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (អាយឆា) ក្នុងឆ្នាំ២០០៩ ដែលជាស្ថាប័នគ្របដណ្តប់ទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ស្របតាមគោលការណ៍និងគោលបំណងនៃធម្មនុញ្ញអាស៊ាន។

ជាមួយវត្តមានរយៈពេល៨ឆ្នាំ អាយឆាសម្រេចបានវឌ្ឍនភាពសំខាន់ៗ ក្នុងការបង្កើតក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សក្នុងអាស៊ាន។ ការអនុម័តលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាននៅឆ្នាំ២០១២ មិនត្រឹមតែបង្កើតក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយសម្រាប់កិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែការអនុម័តនេះបានបង្ហាញគុណតម្លៃបន្ថែមទៀតចំពោះបទដ្ឋានអន្តរជាតិនិងស្តង់ដារសិទ្ធិមនុស្ស។ សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន គូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៃរដ្ឋសមាជិកអាស៊ានក្នុងការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់ប្រជាជនអាស៊ាន។

ជាមួយនឹងភាពចម្រុះនៃនយោបាយក្នុងចំណោមរដ្ឋសមាជិកអាស៊ាន ការលើកកម្ពស់សិទ្ធិមនុស្សត្រូវបានចាត់ទុកថាមានសារៈសំខាន់ ក្នុងការអប់រំនិងការបង្កើនការយល់ដឹងអំពីសិទ្ធិមនុស្សក្នុងចំណោមប្រជាជនអាស៊ាន។ នេះគឺជាការផ្តោតការយកចិត្តទុកដាក់របស់អាយឆានាពេលប៉ុន្មានឆ្នាំនេះ បន្ទាប់ពីគណៈកម្មការនេះត្រូវបានបង្កើតឡើង។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន និងអន្តរសសរស្តម្ភមានកាន់តែច្រើនឡើងៗ ដើម្បីបញ្ជ្រាបសិទ្ធិមនុស្សទៅក្នុងសសរស្តម្ភទាំងអស់របស់អាស៊ាន ដូចជាអំពើជួញដូរមនុស្សនិងពិការភាព ដែលបង្ហាញពីការអភិវឌ្ឍប្រកបដោយភាពជឿជាក់របស់អាយឆា ក្នុងការធ្វើឱ្យមានតុល្យភាពនៃអាណត្តិរបស់អាយឆា ដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស។ ដើម្បីគាំទ្រនិងបង្កើនកម្មវិធីនិងសកម្មភាពរបស់ខ្លួនបន្ថែមទៀត អាយឆាបាន និងកំពុងពង្រីកកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ និងភាគីខាងក្រៅនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

អាយឆាបានរក្សាកិច្ចខិតខំ ដើម្បីរួមចំណែកដល់ការសម្រេចបានសហគមន៍អាស៊ានមួយដែលយកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាធំ។ អាយឆាបាន និងកំពុងមានទំនាក់ទំនងជាមួយសង្គមស៊ីវិលដែលវឌ្ឍនភាពការងារស្ថិតក្នុងដំណាក់កាលផ្សេងៗគ្នា។ ទំនាក់ទំនងរវាងអាយឆា និងសង្គមស៊ីវិល តាមរយៈការផ្តល់ទំនាក់ទំនងលក្ខណៈពិគ្រោះយោបល់ពីអាយឆាជូនអង្គការសង្គមស៊ីវិលនានា ជាការវិវត្តមួយដែលត្រូវបានស្វាគមន៍។

ខ្ញុំប្រាកដណាស់ថា អាយឆានឹងបន្តមាននវានុវត្តន៍ ក្នុងការស្វែងរកយុទ្ធសាស្ត្រឆ្ពោះទៅមុខ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សថ្នាក់តំបន់ និងឆ្លើយតបទនឹងបញ្ហាប្រឈមពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលកំពុងលេចឡើង។ «អាយឆាៈ អ្វីដែលអ្នកត្រូវដឹង - ការបោះពុម្ពផ្សាយខួបលើកទី៥០របស់អាស៊ាន» ជាការចងក្រងដែលពិពណ៌នាអំពីការរៀបចំយ៉ាងទូលំទូលាយមួយនៃរចនាសម្ព័ន្ធ អាណត្តិ និងមុខងាររបស់អាយឆា។ ជាមួយនឹងការធ្វើបច្ចុប្បន្នភាពដែលរួមបញ្ចូលការអភិវឌ្ឍថ្មីៗចាប់តាំងពីចាប់ផ្តើមសហគមន៍អាស៊ានក្នុងឆ្នាំ២០១៥ និងឯកសារមូលដ្ឋានគ្រឹះផ្សេងៗរបស់អាយឆា ដូចជា សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន សេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងលក្ខន្តិកៈរបស់អាយឆា ខ្ញុំជឿជាក់ថា ការចងក្រងនេះនឹងផ្តល់ការយល់ដឹងទូលំទូលាយលើការរួមចំណែករបស់អាយឆា រួមទាំងគោលដៅអនាគតរបស់អាយឆា។

ឡេ ឡួង មិញ
អគ្គលេខាធិការអាស៊ាន

# អាយឆាៈ អ្វីដែលអ្នកត្រូវដឹង

## សេចក្តីផ្តើម

រយៈពេលប្រាំទសវត្សរ៍ចាប់តាំងពីបង្កើតឡើង អាស៊ានដែលជាអង្គការអន្តររដ្ឋាភិបាលមួយ តែងតែខិតខំឆ្ពោះទៅរកការធ្វើឱ្យជីវិតរបស់ប្រជាជននៅក្នុងតំបន់ ជាពិសេសផ្នែកសេដ្ឋកិច្ច សន្តិសុខ-នយោបាយ និងសង្គម-វប្បធម៌ ឱ្យកាន់តែប្រសើរឡើង។ សិទ្ធិមនុស្សគឺជាផ្នែកមួយដ៏សំខាន់នៃសហគមន៍អាស៊ាន ហើយត្រូវបានឆ្លុះបញ្ចាំងនៅក្នុងធម្មនុញ្ញអាស៊ាន (មាត្រា១.៧ ២.២.i និង១៤) ផែនការលម្អិតនយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០០៩-២០១៥ (ផ្នែកA.១.៥) និងផែនការលម្អិតសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ (ផ្នែក A២.៥)។

អាស៊ានបានបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដ៏ខ្លាំង ក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ព្រមទាំងបន្តធានាដល់សុខុមាលភាពរបស់ប្រជាជន។ គណៈកម្មការអន្តរដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (អាយឆា) និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់និងការការពារសិទ្ធិស្ត្រីនិងកុមារត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ និង២០១០ រៀងៗខ្លួន។

អាយឆា ក្នុងនាមជាស្ថាប័នគ្របដណ្តប់លើសិទ្ធិមនុស្សក្នុងតំបន់អាស៊ានជាមួយនឹងអាណត្តិមានលក្ខណៈអន្តរវិស័យ ដែលទទួលបន្ទុកបញ្ហាទាក់ទងនឹងកិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សជាមួយស្ថាប័នអាស៊ាន ដៃគូខាងក្រៅ និងភាគីពាក់ព័ន្ធផ្សេងៗបានកំណត់ទម្រង់សម្រាប់កិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅក្នុងអាស៊ាន។

ប៉ុន្តែតើមានមនុស្សប៉ុន្មាននាក់នៅក្នុងតំបន់អាស៊ានស្គាល់អាយឆា? ហើយតើមានមនុស្សប៉ុន្មាននាក់ដឹងថាតើអាយឆាកើតមកពណា ហើយមានអាណត្តិអ្វីខ្លះ? កូនសៀវភៅនេះមានគោលបំណងផ្តល់ការពន្យល់ខ្លីៗទាក់ទងនឹងអាយឆា និងការអភិវឌ្ឍសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ាន។

### អាស៊ាន

អាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ តាមរយៈការចុះហត្ថលេខាលើសេចក្តីប្រកាសអាស៊ាន (សេចក្តីប្រកាសទីក្រុងបាងកក) ដោយសមាជិកស្ថាបនិកអាស៊ានចំនួន៥ គឺឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ។ សមាជិកភាពបន្ថែមថ្មីចំនួន៥ប្រទេស រួមមានដូចជា ប្រ៊ុយណេដារូសាឡឹម (១៩៨៤) វៀតណាម (១៩៩៥) ឡាវនិងមីយ៉ាន់ម៉ា (១៩៩៧) និងកម្ពុជា (១៩៩៩) បានបង្កើនចំនួនរដ្ឋសមាជិកអាស៊ានរហូតដល់១០ប្រទេស។

គោលបំណងរបស់អាស៊ានដូចមានចែងក្នុងធម្មនុញ្ញអាស៊ាន រួមមានៈ

- រក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព ព្រមទាំងបន្តពង្រឹងគុណតម្លៃនៃការតម្រង់ទិសសន្តិភាពនៅក្នុងតំបន់។
- ជំរុញភាពធន់ថ្នាក់តំបន់តាមរយៈការលើកកម្ពស់ឱ្យកាន់តែប្រសើរឡើងនៃកិច្ចសហប្រតិបត្តិការនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងវប្បធម៌សង្គម។
- ធានាថាប្រជាជន និងរដ្ឋសមាជិកអាស៊ាន រស់នៅក្នុងសន្តិភាពជាមួយពិភពលោកទាំងមូល ក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងសុខដុម។

- កាត់បន្ថយភាពក្រីក្រ និងបង្រួមគម្លាតអភិវឌ្ឍន៍នៅក្នុងអាស៊ាន តាមរយៈការជួយគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ។
- ពង្រឹងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់អភិបាលកិច្ចល្អនិងនីតិរដ្ឋ ព្រមទាំងលើកកម្ពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ដោយផ្អែកលើសិទ្ធិ និងទំនួលខុសត្រូវរបស់រដ្ឋសមាជិកអាស៊ាន ។
- អភិវឌ្ឍធនធានមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធលើវិស័យអប់រំនិងបំនិនជីវិត និងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីផ្តល់កម្លាំងដល់ប្រជាជនអាស៊ាន និងដើម្បីពង្រឹងសហគមន៍អាស៊ាន។
- លើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាជនអាស៊ាន ដោយផ្តល់ឱ្យនូវលទ្ធភាពទទួលបានឱកាសដោយសមភាព សម្រាប់ការអភិវឌ្ឍធនធានមនុស្ស សុខុមាលភាពសង្គម និងយុត្តិធម៌។
- លើកកម្ពស់អាស៊ានដែលយកចិត្តទុកដាក់លើប្រជាជន ដែលគ្រប់វិស័យនៅក្នុងសង្គមទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យចូលរួម និងទទួលបានអត្ថប្រយោជន៍ពីវឌ្ឍភាពនៃសមាហរណកម្មអាស៊ាន និងការកសាងសហគមន៍។
- លើកកម្ពស់អត្តសញ្ញាណអាស៊ានតាមរយៈការលើកតម្កើងការយល់ដឹងកាន់តែខ្លាំងពីវប្បធម៌ចម្រុះនិងបេតិកភ័ណ្ឌនៃតំបន់។

ធម្មនុញ្ញអាស៊ានចូលជាធរមាននៅឆ្នាំ២០០៨ ផ្តល់នូវលក្ខណៈគតិយុត្ត និងក្របខ័ណ្ឌជាស្ថាប័នសម្រាប់អាស៊ាន។ ក្នុងការរៀបចំប្រមូលបទដ្ឋាន វិធាន និងគុណតម្លៃអាស៊ាន ធម្មនុញ្ញក៏បានជានាពីគណនេយ្យភាព និងការអនុលោមទៅតាមច្បាប់ និងការកំណត់គោលដៅច្បាស់លាស់សម្រាប់អាស៊ាន។

អាស៊ានបានប្តេជ្ញាចិត្តបង្កើតសហគមន៍អាស៊ាននៅឆ្នាំ២០១៥ ហើយបានអនុម័ត «ផែនទីចង្អុលផ្លូវសម្រាប់សហគមន៍អាស៊ានឆ្នាំ២០០៩-២០១៥»។ សហគមន៍នេះត្រូវបានគាំទ្រដោយសរសរស្តម្ភសហគមន៍ទាំង៣ ជាមួយនឹងផែនការលម្អិតតាមសហគមន៍ ដូចជាផែនការលម្អិតសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន និងផែនការលម្អិតសហគមន៍សង្គម-វប្បធម៌អាស៊ាន។ សហគមន៍នីមួយៗមានក្រុមប្រឹក្សាសហគមន៍សម្រាប់សម្របសម្រួលកិច្ចការងារតាមវិស័យផ្សេងៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី អាស៊ានបានស្វាគមន៍នូវការបង្កើតសហគមន៍អាស៊ានជាផ្លូវការ និងអនុម័តលើ «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខទាំងអស់គ្នា» ដែលបន្តពីផែនទីចង្អុលផ្លូវខាងលើ។ ឯកសារនេះ រួមមានសេចក្តីប្រកាសទីក្រុងគូឡាឡាំពួស្តីពីអាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខទាំងអស់គ្នា ចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ ផែនការលម្អិតសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និងផែនការលម្អិតសហគមន៍សង្គម-វប្បធម៌អាស៊ានឆ្នាំ២០២៥។ ឯកសារទាំងអស់នេះ នឹងកំណត់ផ្លូវដើរនាទសវត្សរ៍បន្ទាប់ ដើម្បីបន្តពង្រឹងសហគមន៍អាស៊ាន និងផ្តល់លទ្ធភាពឱ្យសម្រេចបាននូវសហគមន៍មួយ ដែលមាននយោបាយប្រទាក់ក្រឡាគ្នា សមាហរណកម្មសេដ្ឋកិច្ច និងទំនួលខុសត្រូវសង្គម មានន័យថា អាស៊ានដែលពិតជាយកចិត្តទុកដាក់លើប្រជាជន យកប្រជាជនជាធំ និងផ្អែកលើច្បាប់។

កិច្ចប្រជុំកំពូលអាស៊ានដែលមានប្រមុខរដ្ឋឬរដ្ឋាភិបាលនៃរដ្ឋជាសមាជិក គឺជាស្ថាប័នបង្កើតគោលនយោបាយខ្ពស់បំផុតនៅក្នុងតំបន់អាស៊ាន។ ប្រមុខរដ្ឋឬរដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ាន ជួបប្រជុំចំនួនពីរដងជារៀងរាល់ឆ្នាំនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន។ ថ្នាក់ដឹកនាំអាស៊ានត្រូវបានគាំទ្រដោយរដ្ឋមន្ត្រីការបរទេសរបស់ខ្លួន ដែលបានជួបប្រជុំក្នុងនាមជាក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន និងនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។ បន្ថែមទៅក្នុងរចនាសម្ព័ន្ធរបស់អាស៊ាន រដ្ឋសមាជិក

អាស៊ានតែងតាំងអ្នកតំណាងប្រចាំអាស៊ាន ដែលមានឋានៈឯកអគ្គរដ្ឋទូត ជាសមាជិកនៃគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍។ គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ មានភារកិច្ចក្នុងការសម្របសម្រួលជាមួយលេខាធិការដ្ឋានជាតិអាស៊ាននិងស្ថាប័នថ្នាក់រដ្ឋមន្ត្រីអាស៊ានតាមវិស័យ និងជួយសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការអាស៊ានជាមួយដៃគូខាងក្រៅ។




ស្ថាប័នដែលគាំទ្រការងារនិងកិច្ចខិតខំក្រោមបន្ទុកអាស៊ានគឺ លេខាធិការដ្ឋានអាស៊ាន។ លេខាធិការដ្ឋានអាស៊ានដឹកនាំដោយអគ្គលេខាធិការអាស៊ាន (ដែលត្រូវបានផ្តល់ឋានៈដូចគ្នាទៅនឹងរដ្ឋមន្ត្រី) ហើយមានការជួយគាំទ្រដោយអគ្គលេខាធិការរងចំនួន៤រូប ដែល១រូបៗសម្រាប់សហគមន៍អាស៊ាននីមួយៗ និង១រូបទៀតសម្រាប់សហគមន៍និងកិច្ចការសាជីវកម្មអាស៊ាន។

## សិទ្ធិមនុស្សលើរបៀបវារៈអាស៊ាន

នៅឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិបានកោះប្រជុំសន្និសីទពិភពលោកស្តីពី សិទ្ធិមនុស្សនៅទីក្រុងវីយែន ប្រទេសអូទ្រីស។ រដ្ឋសមាជិកអាស៊ាន ដែលពេលនោះមានសមាជិកតែ៦ប្រទេសប៉ុណ្ណោះ បានចូលរួមសន្និសីទពិភពលោក។ សន្និសីទបាននាំមកនូវលិទ្ធផល សេចក្តីប្រកាសក្រុងវីយែន និងកម្មវិធីសកម្មភាព។




ជាកិច្ចបន្ទាប់ រដ្ឋមន្ត្រីការបរទេសអាស៊ានក្នុងសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី២៦ (ខែកក្កដា ១៩៩៣) បានថ្លែងដូចខាងក្រោម៖

១៦. រដ្ឋមន្ត្រីការបរទេសស្វាគមន៍ចំពោះកង់សង់ស៊ីសអន្តរជាតិ ដែលសម្រេចបានក្នុងអំឡុងពេលសន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស នៅក្រុងវីយែន កាលពីថ្ងៃទី១៤ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៣ ហើយបានអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្តរបស់អាស៊ាន និងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ដូចដែលបានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងវីយែន ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៣ ។ រដ្ឋមន្ត្រីការបរទេសបានសង្កត់ធ្ងន់ថា សិទ្ធិមនុស្សមានអន្តរទំនាក់ទំនងនិងមិនអាចកាត់ផ្តាច់បាន ដែលរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ សិទ្ធិទាំងនេះមានសារៈសំខាន់ស្មើគ្នា។

សិទ្ធិទាំងនេះគួរតែត្រូវលើកយកមកដោយមានតុល្យភាព និងបែបបទរួមបញ្ចូលតែមួយ ហើយត្រូវបានការពារនិងលើកកម្ពស់តាមរយៈការយកចិត្តទុកដាក់ចំពោះស្ថានភាពវប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយជាក់លាក់។ រដ្ឋមន្ត្រីការបរទេសបានសង្កត់ធ្ងន់ថា ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សមិនគួរត្រូវបានគេធ្វើឱ្យក្លាយទៅជារឿងនយោបាយនោះទេ។

១៧. រដ្ឋមន្ត្រីការបរទេសបានយល់ស្របថា អាស៊ានគួរតែសម្របសម្រួលឱ្យមានវិធីសាស្ត្ររួមស្តីពីសិទ្ធិមនុស្ស និងចូលរួមយ៉ាងសកម្ម និងរួមចំណែកដល់ការអនុវត្ត ការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស។ រដ្ឋមន្ត្រីការបរទេសបានកត់សម្គាល់ទៀតថា ធម្មនុញ្ញអង្គការសហប្រជាជាតិបានដាក់ជាសំណួរនៃការអនុវត្តប្រតិបត្តិតាមសិទ្ធិមនុស្សជាសាកល និងការលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងបរិបទនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។ រដ្ឋមន្ត្រីការបរទេសបានសង្កត់ធ្ងន់ថា ការអភិវឌ្ឍ គឺជាសិទ្ធិមិនអាចដកហូតបាន ហើយការប្រើប្រាស់សិទ្ធិមនុស្សដែលជាលក្ខខណ្ឌមួយដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍ គឺបង្កជាគ្រោះថ្នាក់ដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងអាចធ្វើឱ្យចុះខ្សោយដល់កុងសង់ស៊ីសអន្តរជាតិលើសិទ្ធិមនុស្ស។ រដ្ឋមន្ត្រីការបរទេសបានគូសបញ្ជាក់ថា ការការពារនិងការលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងសហគមន៍អន្តរជាតិគួរតែពិចារណាទៅលើគោលការណ៍នៃការគោរពអធិបតេយ្យជាតិ បូរណភាពដែនដី និងការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់បណ្តារដ្ឋ។ រដ្ឋមន្ត្រីការបរទេសជឿជាក់ថា សេរីភាព វឌ្ឍនភាព និងស្ថិរភាពជាតិ ត្រូវបានលើកកម្ពស់ដោយផ្អែកលើតុល្យភាពរវាងសិទ្ធិបុគ្គល និងសិទ្ធិសហគមន៍ តាមរយៈសិទ្ធិបុគ្គលជាច្រើនត្រូវបានយល់ដឹង ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

១៨. រដ្ឋមន្ត្រីការបរទេសបានពិនិត្យឡើងវិញយ៉ាងពេញចិត្តនៃការបន្តវឌ្ឍភាពគួរឱ្យកត់សម្គាល់របស់អាស៊ាន ក្នុងការធ្វើឱ្យប្រជាជនរបស់ខ្លួនរួចផុតពីការភ័យខ្លាច និងការចង់បាន ដែលអាចឱ្យពួកគេរស់នៅក្នុងសេចក្តីថ្លៃថ្នូរ។ រដ្ឋមន្ត្រីការបរទេសបានសង្កត់ធ្ងន់ថាការរំលោភបំពានមូលដ្ឋាននៃសិទ្ធិមនុស្ស ត្រូវតែដោះស្រាយ និងមិនត្រូវអត់ឱនក្រោមលេសណាមួយទេ។ រដ្ឋមន្ត្រីការបរទេសបានបញ្ជាក់បន្ថែមទៀត អំពីសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើគ្រប់ទិដ្ឋភាពទាំងអស់នៃសិទ្ធិមនុស្ស ហើយរដ្ឋាភិបាលទាំងអស់គួរតែប្រកាន់ខ្ជាប់បទដ្ឋានមនុស្សធម៌ និងគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ក្នុងន័យនេះ និងដើម្បីគាំទ្រសេចក្តីប្រកាសទីក្រុងវីយែននិងកម្មវិធីសកម្មភាពថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ១៩៩៣ រដ្ឋមន្ត្រីការបរទេសបានឯកភាពថាអាស៊ាន ក៏គួរតែពិចារណាលើការបង្កើតយន្តការតំបន់សមរម្យមួយស្តីពីសិទ្ធិមនុស្ស។ នេះជាលើកទីមួយហើយដែលអាស៊ានបានកំណត់ឆ្ពោះទៅរកការអភិវឌ្ឍរបបសិទ្ធិមនុស្សក្នុងតំបន់។

កិច្ចប្រជុំកំពូលក្រៅផ្លូវការអាស៊ានលើកទី២ ដែលបានប្រារព្ធឡើងនៅទីក្រុងគូឡាឡាំពួនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ បានអនុម័តលើចក្ខុវិស័យអាស៊ានឆ្នាំ២០២០ដែលកំណត់ចក្ខុវិស័យដ៏ទូលំទូលាយសម្រាប់អាស៊ាននៅឆ្នាំ២០២០៖ អាស៊ានគឺជាការព្រមព្រៀងរបស់ប្រជាជាតិអាស៊ីអាគ្នេយ៍ សម្លឹងឆ្ពោះទៅខាងក្រៅ ការរស់នៅក្នុងសន្តិភាព ស្ថិរភាព និងវិបុលភាពបានផ្សារភ្ជាប់គ្នាក្នុងភាពជាដៃគូក្នុងការអភិវឌ្ឍប្រកបដោយថាមភាព និងនៅក្នុងសហគមន៍សង្គមដែលយកចិត្តទុកដាក់។ ដើម្បីអនុវត្តចក្ខុវិស័យវែងឆ្ងាយ ផែនការសកម្មភាពទីក្រុងហាណូយឆ្នាំ១៩៩៧ ត្រូវបានបង្កើតឡើង។

ក្រោមផ្នែកទី៤ កថាខ័ណ្ឌទី៤.៨ នៃផែនការសកម្មភាពទីក្រុងហាណូយ អាស៊ានប្តេជ្ញាចិត្តជំរុញការផ្លាស់ប្តូរព័ត៌មានក្នុងវិស័យសិទ្ធិមនុស្សក្នុងចំណោមរដ្ឋសមាជិកអាស៊ាន ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ប្រជាជនទាំងអស់ដោយស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសសិទ្ធិមនុស្សជាសកល និងសេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាព។

ដើម្បីគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យអាស៊ានឆ្នាំ២០២០ រដ្ឋសមាជិកអាស៊ានបានរៀបចំកម្មវិធីសកម្មភាពទីក្រុងវៀងចន្ទន៍ឆ្នាំ២០០៤។ តាមកម្មវិធីសកម្មភាព នៅផ្នែកខាងក្រោម «ការអភិវឌ្ឍនយោបាយ» រដ្ឋជាសមាជិកយល់ព្រម «លើកកម្ពស់សិទ្ធិមនុស្ស និងកាតព្វកិច្ច»។

ប្រាំឆ្នាំក្រោយមក រដ្ឋជាសមាជិកបានសម្រេច ក្នុងការពន្លឿនការបង្កើតសហគមន៍អាស៊ានត្រឹមឆ្នាំ២០១៥។ រដ្ឋជាសមាជិកបានអនុម័តលើ ផែនទីចង្អុលផ្លូវសម្រាប់សហគមន៍អាស៊ាន២០០៩-២០១៥ និងផែនការលម្អិតសហគមន៍អាស៊ានចំនួន៣។

សមាសភាពសិទ្ធិមនុស្ស ដែលមាននៅក្នុងកម្មវិធីសកម្មភាពទីក្រុងវៀងចន្ទន៍ឆ្នាំ២០០៤ ត្រូវបានបញ្ជាក់ជាថ្មីនៅក្នុងកម្មវិធីសកម្មភាព ក្រោមផែនការលម្អិតសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០០៩-២០១៥ ផ្នែកA.១.៥. «ការលើកកម្ពស់ និងការការពារសិទ្ធមនុស្ស» ដែលមានបន្ទាត់សកម្មភាពចំនួនប្រាំពីរ ។


*អាយឆា និងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន*

ការប្តេជ្ញាចិត្តរបស់អាស៊ាន ដើម្បីសម្រេចបាននូវសហគមន៍មួយដែលប្រកបដោយបរិយាប័ន្ននិងការឆ្លើយតបខ្ពស់ ដែលធានាដល់ការទទួលបានអត្ថប្រយោជន៍របស់ប្រជាជនពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន គឺត្រូវបានបញ្ជាក់បន្ថែមនៅក្នុងផែនការលម្អិតសហគមន៍សន្តិសុខ-នយោបាយអាស៊ានឆ្នាំ២០២៥ ផ្នែកA.2.5 «លើកកម្ពស់ និងការពារសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន និងយុត្តិធម៌សង្គម ដើម្បីធានាដល់ប្រជាជនរបស់យើងរស់នៅក្នុងសេចក្តីថ្លៃថ្នូរ នៅក្នុងសន្តិភាព ភាពសុខដុម និងវិបុលភាព» ជាមួយនឹងបន្ទាត់សកម្មភាពដូចខាងក្រោម៖

**សកម្មភាព៖**

i. លើកទឹកចិត្តរដ្ឋសមាជិកអាស៊ាន ដើម្បីពង្រឹងបទដ្ឋានគតិយុត្តនិងស្ថាប័នក្នុងស្រុក លើកកម្ពស់ការអប់រំសិទ្ធិមនុស្ស និងបន្តកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ
ii. លើកទឹកចិត្តរដ្ឋសមាជិកអាស៊ាន ឱ្យផ្តល់សច្ចាប័ន ឬចូលជាភាគីលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ និងធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព
iii. លើកទឹកចិត្តរដ្ឋសមាជិកអាស៊ានក្នុងការជំរុញទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ និងយន្តការសិទ្ធិមនុស្ស ដែលពាក់ព័ន្ធ ដែលរដ្ឋសមាជិកអាស៊ានជាភាគី រួមមានការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល (UPR) និងស្ថាប័នសន្ធិសញ្ញាដែលពាក់ព័ន្ធ ព្រមទាំងចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗ
iv. គាំទ្រគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (អាយឆា) ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន អនុលោមតាមលក្ខខណ្ឌ
v. ជំរុញការផ្លាស់ប្តូរព័ត៌មានស្តីពីកិច្ចប្រឹងប្រែង ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាននៅក្នុងចំណោមរដ្ឋជាសមាជិកដោយអនុលោមទៅតាមធម្មនុញ្ញអាស៊ាន សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ព្រមទាំងបណ្តាសេចក្តីប្រកាសសិទ្ធិមនុស្ស និងលិខិតុបករណ៍អន្តរជាតិដែលរដ្ឋសមាជិកអាស៊ានជាភាគី

vi. ពង្រឹងការអនុវត្តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ដែលរួមបញ្ចូលការផ្សព្វផ្សាយព័ត៌មាន និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈលើសេចក្តីប្រកាសនេះ

vii. លើកកម្ពស់ការបញ្ជ្រាបសិទ្ធិមនុស្សដល់សសរស្តម្ភទាំងបីនៃសហគមន៍អាស៊ាន តាមរយៈការពិគ្រោះយោបល់ក្នុងចំណោមស្ថាប័នអាស៊ានពាក់ព័ន្ធ

viii. លើកទឹកចិត្តដល់អន្តរទំនាក់ទំនង និងការពិគ្រោះយោបល់ដែលសមស្របក្នុងចំណោមអាយឆា ស្ថាប័នអាស៊ានពាក់ព័ន្ធ និងភាគីពាក់ព័ន្ធដទៃទៀត ដែលរួមបញ្ចូលអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធនឹងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស

ix. បន្តការងាររបស់អាយឆា ក្នុងការរៀបចំកិច្ចការស្រាវជ្រាវដែលមានលក្ខណៈសហការគ្នាលើប្រធានបទបញ្ហាសិទ្ធិមនុស្សដោយយោងទៅតាមលក្ខន្តិកៈរបស់អាយឆា

x. បន្តការងាររបស់អាយឆា ក្នុងការទទួលបានព័ត៌មានពីបណ្តារដ្ឋសមាជិកអាស៊ាន ស្តីពីការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស

xi. ជំរុញការយល់ដឹងជាសាធារណៈស្តីពីសិទ្ធិមនុស្សក្នុងចំណោមប្រជាជនអាស៊ាន រួមមានការបោះពុម្ពផ្សាយការធ្វើបច្ចុប្បន្នភាពជាទៀងទាត់នៃសកម្មភាពរបស់អាយឆា និងសកម្មភាពព័ត៌មានជាសាធារណៈដោយស្ថាប័នអាស៊ានដែលពាក់ព័ន្ធ

xii. ពិចារណាក្នុងការត្រួតពិនិត្យឡើងវិញនូវលក្ខន្តិកៈរបស់អាយឆា ដូចមានចែងនៅក្នុងលក្ខន្តិកៈ ដែលស្របតាមគោលបំណងនិងគោលការណ៍ធម្មនុញ្ញអាស៊ាន ជាមួយនឹងទស្សនវិស័យដើម្បីបន្តបង្កើនការលើកកម្ពស់និងការពារសិទ្ធិមនុស្សនៅក្នុងអាស៊ាន ក្នុងពេលសមស្របណាមួយ។

xiii. ពង្រឹងទំនាក់ទំនងរវាងបណ្តាញយន្តការសិទ្ធិមនុស្សដែលមាន ក៏ដូចជាអង្គការសង្គមស៊ីវិលដទៃទៀត ជាមួយនឹងបណ្តាស្ថាប័នតាមវិស័យរបស់អាស៊ាន។

xiv. លើកទឹកចិត្តដល់ការសម្របសម្រួល និងពិគ្រោះយោបល់ក្នុងចំណោមអង្គភាពនិងស្ថាប័នអាស៊ានដែលពាក់ព័ន្ធដើម្បីជំរុញការអនុវត្តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន សេចក្តីប្រកាសទីក្រុងហាណូយស្តីពីការលើកកម្ពស់សុខុមាលភាពនិងការអភិវឌ្ឍស្ត្រីនិងកុមារអាស៊ាន ព្រមទាំងសេចក្តីប្រកាសបាលីស្តីពីការជំរុញតួនាទី និងការចូលរួមរបស់ជនពិការនៅក្នុងសហគមន៍អាស៊ាន ខណៈដែលរក្សាប្រពន្ធ័រាយការណ៍ លំដាប់លំដោយរបស់ខ្លួនរៀងៗខ្លួននិង

xv. សហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នតាមវិស័យពាក់ព័ន្ធ ខណៈដែលរក្សារបាយការណ៍តាមលំដាប់នីមួយៗដើម្បីពន្លឿនការងាររបស់គណៈកម្មាធិការអាស៊ានលើការអនុវត្តសេចក្តីប្រកាស ស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍ក្នុងការបង្កើតលិខិតុបករណ៍ ដើម្បីធានាថាសិទ្ធិរបស់ពលករទេសន្តប្រវេសន៍ត្រូវបានការពារយ៉ាងល្អនៅក្នុងតំបន់ ស្របតាមច្បាប់ វិធាន និងគោលនយោបាយរបស់រដ្ឋជាសមាជិកនីមួយៗ។

## AICHR **អាយឆា**

«ដោយអនុលោមតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអាស៊ានដែលទាក់ទងនឹងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន អាស៊ានត្រូវបង្កើតអង្គភាពសិទ្ធិមនុស្សអាស៊ានមួយ» (ធម្មនុញ្ញអាស៊ាន មាត្រា១៤)។

ក្រុមការងារជាន់ខ្ពស់ទទួលបន្ទុកអង្គភាពសិទ្ធិមនុស្សអាស៊ានបានធ្វើសេចក្តីព្រាងលក្ខន្តិកៈរបស់អាយឆា ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅខែកក្កដា ឆ្នាំ២០០៩។ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ អ្នកតំណាងអាយឆាចំនួន១០រូប ដែលមួយរូបៗមកពីរដ្ឋសមាជិកនីមួយៗត្រូវបានតែងតាំង ហើយអាយឆាត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅកិច្ចប្រជុំកំពូលអាស៊ានលើកទី១៥ នៅឆាអាំ-ហួហ៊ីន ប្រទេសថៃ។

នៅក្នុងសេចក្តីប្រកាសឆាអាំ-ហួហ៊ីនស្តីពីការប្រកាសដាក់ឱ្យដំណើរការជាផ្លូវការរបស់អាយឆា ប្រមុខដឹកនាំអាស៊ានបានថ្លែងថា អាយឆាគឺជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលក្នុងចំណោមរដ្ឋសមាជិកអាស៊ានទាំង១០ ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស។ ការបង្កើតអាយឆាបង្ហាញពីការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការបន្តយុទ្ធសាស្ត្រឆ្ពោះទៅមុខ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស។ អាយឆាត្រូវបានបង្កើតឡើងជាចំណែកមួយនៃរចនាសម្ព័ន្ធចាត់តាំងអាស៊ាន និងជាស្ថាប័នគ្របដណ្តប់ជាមួយនឹងការទទួលខុសត្រូវជារួម សម្រាប់ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ាន។ សេចក្តីសម្រេចរបស់អាយឆា គឺផ្អែកលើការពិគ្រោះយោបល់និងកុងសង់ស៊ីស។ អាយឆាចូលរួមកិច្ចសន្ទនា និងកិច្ចពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនឹងអាស៊ាន ហើយក៏ពិគ្រោះយោបល់ជាមួយស្ថាប័នថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និងអង្គភាពដែលពាក់ព័ន្ធនឹងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សផងដែរ។

អាយឆា មានកិច្ចប្រជុំ២ដងក្នុងមួយឆ្នាំ និងកិច្ចប្រជុំបន្ថែមទៀតប្រសិនបើមានភាពចាំបាច់។ អាយឆា បានបង្កើតនូវឯកសារគ្រឹះមួយចំនួន ចាត់ទុកជា ក្របខ័ណ្ឌ និងមូលដ្ឋានគ្រឹះសម្រាប់ប្រព្រឹត្តកម្មរបស់អាយឆាដូចជា៖

- ផែនការការងារប្រាំឆ្នាំរបស់អាយឆាឆ្នាំ២០១០-២០១៥ ផែនការការងារប្រាំឆ្នាំរបស់អាយឆាឆ្នាំ២០១៦-២០២០ និងថវិកាជាក់លាក់
- កម្មវិធី/សកម្មភាពអាទិភាពរបស់អាយឆា (ឆ្នាំ២០១០-២០១១ ២០១២ ២០១៣ ២០១៤ ២០១៥ ២០១៦ និង២០១៧) ជាមួយនឹងថវិកាប្រចាំឆ្នាំនីមួយៗ
- គោលការណ៍ណែនាំស្តីពីប្រតិបត្តិការរបស់អាយឆា (ដែលស្គាល់ថាជាគោលការណ៍ណែនាំរបស់អាយឆា)
- ច្បាប់នៃនីតិវិធីរបស់មូលនិធិអាយឆា (ដែលស្គាល់ថាជា ROP នៃមូលនិធិអាយឆា)
- គោលការណ៍ណែនាំស្តីពីស្តង់ដារថវិកា
- គោលការណ៍ណែនាំស្តីពីក្រុមនិពន្ធរបស់គេហទំព័រអាយឆា
- គោលការណ៍ណែនាំស្តីពីទំនាក់ទំនងសមស្របរវាងអាយឆា និងអង្គភាពអាស៊ានតាមវិស័យ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស
- គោលការណ៍ណែនាំស្តីពីទំនាក់ទំនងរបស់អាយឆាជាមួយនឹងបណ្តាអង្គការសង្គមស៊ីវិល និង
- ច្បាប់នីតិវិធីនៃកម្មវិធីគណនីអាយឆា(ត្រូវបានស្គាល់ថា ROP នៃកម្មវិធីគណនីរបស់អាយឆា)

*ASEAN Foreign Ministers' Interface with the Representatives of the AICHR at the 48th ASEAN Foreign Ministers' Meeting*

*ជំនួបរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងអាយឆា នៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៨*




អាណត្តិ និងមុខងាររបស់អាយឆា

លក្ខន្តិករបស់អាយឆាមានរួមបញ្ចូលអាណត្តិរបស់អាយឆាចំនួន១៤៖

១. បង្កើតយុទ្ធសាស្ត្រសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដើម្បីបំពេញបន្ថែមការកសាងសហគមន៍អាស៊ាន

២. បង្កើតសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានមួយ ក្នុងគោលបំណងបង្កើតក្របខ័ណ្ឌមួយសម្រាប់កិច្ចសហប្រតិបត្តិការសិទ្ធិមនុស្ស តាមរយៈអនុសញ្ញាអាស៊ានផ្សេងៗ និងលិខិតុបករណ៍ផ្សេងទៀត ពាក់ព័ន្ធសិទ្ធិមនុស្ស

៣. ជំរុញការយល់ដឹងជាសាធារណៈពីសិទ្ធិមនុស្សក្នុងចំណោមប្រជាជនអាស៊ាន តាមរយៈការអប់រំ ការស្រាវជ្រាវ និងការផ្សព្វផ្សាយព័ត៌មាន

៤. លើកកម្ពស់ការកសាងសមត្ថភាពសម្រាប់ការអនុវត្តកាតព្វកិច្ច នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព ដែលអនុវត្តដោយរដ្ឋជាសមាជិកអាស៊ាន

៥. លើកទឹកចិត្តដល់រដ្ឋសមាជិកអាស៊ាន ក្នុងការពិចារណាចូលជាភាគីក្នុង និងផ្តល់សច្ចាប័នលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា

៦. លើកកម្ពស់ការអនុវត្តពេញលេញនៃលិខិតុបករណ៍អាស៊ានពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស

៧. ផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសទៅលើបញ្ហាសិទ្ធិមនុស្សទៅអង្គភាពអាស៊ានតាមវិស័យ តាមការស្នើសុំ

៨. ចូលរួមកិច្ចសន្ទនា និងការប្រឹក្សាយោបល់ជាមួយបណ្តាអង្គភាពអាស៊ាន និងអង្គភាពពាក់ព័ន្ធជាមួយអាស៊ាន ដោយរួមទាំងអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត ដូចមានចែងក្នុងជំពូកទី៥នៃធម្មនុញ្ញអាស៊ាន

៩. ប្រឹក្សាយោបល់ ជាមួយស្ថាប័នជាតិ តំបន់ និងអន្តរជាតិដទៃទៀត ព្រមទាំងស្ថាប័នផ្សេងៗដែលទាក់ទងនឹងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ក្នុងពេលសមស្រប

១០. ទទួលព័ត៌មានពីបណ្តារដ្ឋសមាជិកអាស៊ាន ស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស

១១. បង្កើតវិធីសាស្ត្រ និងជំហររួមលើបញ្ហាសិទ្ធិមនុស្ស ដែលជាអត្ថប្រយោជន៍ចអាស៊ាន

១២. រៀបចំការសិក្សា ស្តីពីប្រធានសិទ្ធិមនុស្សក្នុងតំបន់អាស៊ាន

១៣. ដាក់របាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពរបស់ខ្លួន ឬរបាយការណ៍ផ្សេងៗប្រសិនបើចាំបាច់ ជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និង

១៤. ប្រតិបត្តិការកិច្ចផ្សេងទៀតប្រគល់ឱ្យទៅអាយឆា ដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។

អ្នកតំណាងនីមួយៗរបស់អាយឆា ត្រូវបានតែងតាំងដោយរដ្ឋាភិបាលខ្លួន សម្រាប់អាណត្តិរយៈពេលបីឆ្នាំ ហើយអាចបន្តជាថ្មីឡើងវិញបានម្តង។ តំណាងអាយឆា ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ត្រូវប្រតិបត្តិដោយមិនលម្អៀង ស្របតាមធម្មនុញ្ញអាស៊ាន និងលក្ខន្តិករបស់អាយឆា។

លក្ខន្តិកៈរបស់អាយឆាក៏កំណត់ចេញនូវរបៀបរបបនៃការរាយការណ៍របស់អាយឆា ការរៀបចំកិច្ចប្រជុំ តួនាទីរបស់ប្រធានអាយឆា នីតិវិធីនៃការធ្វើសេចក្តីសម្រេច ការចេញផ្សាយព័ត៌មានសាធារណៈ និងទំនាក់ទំនងរបស់អាយឆាជាមួយអង្គភាពសិទ្ធិមនុស្សផ្សេងទៀតនៅក្នុងតំបន់អាស៊ាន។

លក្ខន្តិករបស់អាយឆាមាននៅលើគេហទំព័រ asean.org។ អ្នកក៏អាចបើកគេហទំព័រថ្នាក់តំបន់របស់អាយឆានៅ aichr.org។

## កម្មវិធី និងសកម្មភាពរបស់អាយឆា

វិស័យអាទិភាពរបស់អាយឆាស្តីពីសិទ្ធិមនុស្សមាននៅក្នុងផែនការការងារប្រាំឆ្នាំ ដែលផ្អែកលើអាណត្តិទាំង១៤របស់អាយឆាដូចបានរៀបរាប់នៅក្នុងលក្ខន្តិករបស់ខ្លួន។ ជារៀងរាល់ឆ្នាំ អាយឆាកំណត់កម្មវិធី និងសកម្មភាពអាទិភាពរបស់ខ្លួនសម្រាប់មួយឆ្នាំ ដែលផ្អែកលើផែនការការងារនិងឆ្លើយតបទៅនឹងតម្រូវការចាំបាច់ដែលលេចឡើងស្តីពីសិទ្ធិមនុស្សនៅក្នុងតំបន់។ អាយឆាបានបញ្ចប់នូវផែនការការងារប្រាំឆ្នាំដំបូងឆ្នាំ២០១០-២០១៥ របស់ខ្លួនហើយ។

អាយឆាបានចាប់ផ្តើមអនុវត្តផែនការការងារប្រាំឆ្នាំ ឆ្នាំ២០១៦-២០២០ លើកទី២ ដែលត្រូវបានអនុម័តនៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៨។ ផែនការការងារប្រាំឆ្នាំលើកទីពីរ ជាការបន្តលើផែនការការងារប្រាំឆ្នាំលើកដំបូង ដើម្បីបន្តលើកកម្ពស់ និងអនុវត្តនូវសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន។ ផែនការប្រាំឆ្នាំនេះ ក៏មានគោលបំណងជំរុញបន្ថែម នូវការរួមសហការគ្នារវាងអាយឆា និងស្ថាប័ននិងអង្គភាពអាស៊ានពាក់ព័ន្ធ ដើម្បីបញ្ជ្រាបសិទ្ធិមនុស្សនៅក្នុងសសរស្តម្ភទាំងបីរបស់អាស៊ាន។

បណ្តាសកម្មភាពរបស់អាយឆាក្នុងរយៈពេលខ្លី និងមធ្យម ក្នុងចំណោមសកម្មភាពដទៃទៀត រួមមាន៖

- អនុវត្តការវាយតម្លៃតម្រូវការសម្រាប់ការកសាងសមត្ថភាព
- បញ្ចប់បញ្ជីនៃលិខិតុបករណ៍សិទ្ធិមនុស្សដែលមានស្រាប់ ដែលត្រូវបានចូលជាភាគី និងផ្តល់លើសច្ចាប័នដោយរដ្ឋសមាជិកអាស៊ាន
- រៀបចំសិក្ខាសាលាលើប្រធានបទផ្សេងៗដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស



- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សសម្រាប់ក្រុមគោលដៅជាក់លាក់ ដូចជាមន្ត្រីរាជការ មន្ត្រីអនុវត្តច្បាប់ អ្នកសារព័ត៌មាន ជាដើម។
- ពង្រឹងការគាំទ្ររបស់លេខាធិការដ្ឋានអាស៊ានសម្រាប់អាយឆា
- ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការងាររបស់អាយឆា រួមទាំងការបោះពុម្ពផ្សាយជាភាសាអង់គ្លេសនិងភាសាជាតិរបស់រដ្ឋសមាជិកអាស៊ាន
- ចែករំលែកឧត្តមានុវត្តនៃការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវកាតព្វកិច្ចរបស់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិក្នុងចំណោមរដ្ឋសមាជិកអាស៊ាន
- សម្របសម្រួល និងប្រឹក្សាយោបល់ជាមួយស្ថាប័នអាស៊ានពាក់ព័ន្ធ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវលិខិតុបករណ៍អាស៊ានដែលពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស
- កំណត់នូវបញ្ហាសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន និងមានសក្តានុពលពាក់ព័ន្ធនឹងអាស៊ាន
- បង្កើតផែនការសកម្មភាព អនុសាសន៍ ឬក្របខ័ណ្ឌគោលនយោបាយអាស៊ានថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្សសម្រាប់ស្ត្រីកុមារនិងជនមានពិការភាព ដើម្បីបញ្ជ្រាបនិងលើកកម្ពស់សិទ្ធិមនុស្សទៅទូទាំងសសរស្តម្ភសហគមន៍ អង្គភាព និងស្ថាប័ន
- ទំនាក់ទំនងក្នុងបណ្តាកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធក្នុងតំបន់ ស្តីពីបញ្ហាសិទ្ធិមនុស្សដែលកំពុងលេចឡើងពាក់ព័ន្ធនឹងអាស៊ាន ដែលស្របនឹងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ដោយអនុលោមតាមសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន សេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងលក្ខន្តិករបស់អាយឆា
- រៀបចំការសិក្សាអំពីប្រធានបទសិទ្ធិមនុស្សក្នុងអាស៊ាន និង
- ពិភាក្សា និងពិគ្រោះយោបល់ជាមួយសហគមន៍ទាំងបីលើសកម្មភាពរបស់ពួកគេរៀងៗខ្លួន ដែលមាននៅក្នុងចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងផែនការលម្អិតសហគមន៍ឆ្នាំ២០២៥ ពាក់ព័ន្ធនឹងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។

វត្តមានរបស់អាយឆាក្នុងរយៈពេល៨ឆ្នាំ អាយឆានៅតែរឹងមាំក្នុងការខិតខំឆ្ពោះទៅរកការលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងអាស៊ាន។ ការទទួលស្គាល់ថាការលើកកម្ពស់សិទ្ធិមនុស្ស និងការការពារសិទ្ធិមនុស្សនៅក្នុងអាស៊ានអាចដោះស្រាយបានទាំងស្រុង តែតាមរយៈកិច្ចសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងស្ថាប័នអាស៊ាន អាយឆាបានអនុម័តគោលការណ៍ណែនាំស្តីពីទំនាក់ទំនងរវាងអាយឆា និងអង្គភាពជំនាញអាស៊ានពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ តាមរយៈការអនុម័តគោលការណ៍ណែនាំនេះ អាយឆាមានគោលបំណងលើកកម្ពស់កិច្ចសហការ និងភាពស្អិតរមួតជាមួយបណ្តាស្ថាប័ននៅក្នុងតំបន់អាស៊ានដទៃទៀតដែលពាក់ព័ន្ធសិទ្ធិមនុស្ស រួមមានគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រីនិងកុមារ គណៈកម្មាធិការអាស៊ានស្តីពីស្ត្រី ក៏ដូចជាគណៈកម្មាធិការអាស៊ានស្តីពីការអនុវត្តសេចក្តីប្រកាសអាស៊ានស្តីពីការលើកការពារនិងការលើកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។ អាយឆាក៏ធ្វើការជាមួយស្ថាប័ន និងអង្គភាពអាស៊ានពាក់ព័ន្ធ ដោយផ្តោតលើបញ្ហាសិទ្ធិមនុស្ស ឧទាហរណ៍ជាមួយកិច្ចប្រជុំឧត្តមមន្ត្រីស្តីពីបទឧក្រិដ្ឋកម្មឆ្លងដែនស្តីពីការជួញដូរមនុស្ស។

# សេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន

មាត្រា៤.២នៃលក្ខន្តិកៈអាយឆាចែងថា អាយឆាត្រូវបានគេផ្ដល់អាណត្តិដើម្បីបង្កើតសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ានមួយ ជាមួយនឹងទស្សនវិស័យមួយដើម្បីបង្កើតក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សតាមរយៈអនុសញ្ញាអាស៊ានផ្សេងៗ និងលិខិតុបករណ៍អាស៊ានដទៃទៀតដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

ក្នុងឆ្នាំ២០១១ អាយឆាបានចាប់ផ្ដើមអនុវត្តអាណត្តិនេះ ដោយធ្វើការរៀបចំក្រុមពង្រាងដើម្បីត្រៀមរៀបចំសេចក្ដីព្រាងគោល នៃសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន។ នៅពេលទទួលបានសេចក្ដីព្រាងគោលពីក្រុមពង្រាង អាយឆាបានដាក់ របាយការណ៍ វឌ្ឍនភាពដំបូងរបស់ខ្លួនស្ដីពីការពង្រាងសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ានជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស នៅកិច្ចប្រជុំចង្អៀត រដ្ឋមន្ត្រីការបរទេសនៅខែមករា ឆ្នាំ២០១២។ នៅក្នុងរបាយការណ៍វឌ្ឍនភាពដំបូងរបស់ខ្លួន អាយឆាបានរៀបចំដំណើរឆ្ពោះ ទៅមុខ ក្នុងការពង្រាងសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន ដែលរួមបញ្ចូលកាលវិភាគនៃកិច្ចប្រជុំជាប្រចាំពាក់ព័ន្ធនឹងការពង្រាង សេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ រួមមានអ្នកជំនាញផ្នែកសិទ្ធិមនុស្ស ការដាក់របាយការណ៍ វឌ្ឍនភាពជូនទៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសពិនិត្យ និងការកំណត់ពេលវេលានៃការដាក់កំណែចុងក្រោយនៃសេចក្ដីប្រកាស សិទ្ធិមនុស្សអាស៊ានជូនទៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមុនកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ នៅខែវិច្ឆិកា ឆ្នាំ២០១២។

នៅក្នុងការព្រាងសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន អាយឆាបានពិគ្រោះយោបល់ និងពិភាក្សាជាមួយតំណាងអង្គភាព តាមវិស័យរបស់អាស៊ាន អង្គការសង្គមស៊ីវិលថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និងអ្នកជំនាញផ្នែកសិទ្ធិមនុស្ស។ អាយឆាមាន សេចក្ដីសោមនស្សយ៉ាងខ្លាំងចំពោះការចូលរួម និងការរួមចំណែកពីសំណាក់តំណាងអង្គភាពតាមវិស័យ អង្គការសង្គមស៊ីវិល និងអ្នកជំនាញទាំងអស់ ដែលបានជួយបង្កើតសេចក្ដីព្រាងនៃសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន ឱ្យជាសេចក្ដីប្រកាស មានភាពគ្រប់ជ្រុងជ្រោយ ដែលឆ្លុះបញ្ចាំងមិនត្រឹមតែបំណងប្រាថ្នារបស់ប្រជាជនអាស៊ានប៉ុណ្ណោះទេ ប៉ុន្តែក៏បន្ថែមតម្លៃ ដល់បទដ្ឋាននិងបទប្បញ្ញត្តិសិទ្ធិមនុស្សអន្តរជាតិ ដោយការដាក់បញ្ចូលនូវសិទ្ធិទទួលបានសន្តិភាព សិទ្ធិទទួលបានការអភិវឌ្ឍ និងការជៀសវាងពីការមាក់ងាយចំពោះអ្នកដែលរងគ្រោះពីជម្ងឺឆ្លងដូចជាមេរោគហ៊ីវជាដើម។

អាយឆាបានដាក់សេចក្ដីព្រាងសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ានដំបូងទៅកាន់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស នៅកិច្ចប្រជុំ រដ្ឋមន្ត្រីការបរទេសលើកទី៤៥ នៅខែកក្កដា ឆ្នាំ២០១២។ ជាមួយការដាក់ជូនសេចក្ដីព្រាងដំបូងនេះ អាយឆាបានស្វែងរក ការណែនាំ និងការចង្អុលបន្ថែមពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសលើដំណាក់កាលបន្ទាប់នៅក្នុងការព្រាងសេចក្ដីប្រកាស សិទ្ធិមនុស្សអាស៊ាន។ សេចក្ដីព្រាងនៃសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ានលើកទី២ដែលបានកែតម្រូវត្រូវបានដាក់បង្ហាញ ជូនរដ្ឋមន្ត្រីការបរទេសកំឡុងពេលកិច្ចប្រជុំក្រៅផ្លូវការ នៅខែកញ្ញា ឆ្នាំ២០១២ មុននឹងដាក់ជូនថ្នាក់ដឹកនាំអាស៊ាន។ ថ្នាក់ដឹកនាំអាស៊ានបានអនុម័តសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាននៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ និងបានចុះហត្ថលេខា លើ«សេចក្ដីថ្លែងការណ៍ភ្នំពេញស្ដីពីការអនុម័តសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន» (សេចក្ដីថ្លែងការណ៍ភ្នំពេញ)។ សេចក្ដី ប្រកាសសិទ្ធិមនុស្សអាស៊ានគឺជាឯកសារអាស៊ានដ៏សំខាន់មួយ ដែលកំណត់ក្របខ័ណ្ឌសម្រាប់ការលើកកម្ពស់និងការពារ សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងតំបន់បន្ថែមទៀត។ សេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន តំណាងឱ្យសេចក្ដីប្រាថ្នា និងការប្ដេជ្ញាចិត្តរបស់រដ្ឋសមាជិកអាស៊ាននិងប្រជារាស្ត្ររបស់ខ្លួនសម្រាប់សហគមន៍អាស៊ានដែលយកចិត្តទុកដាក់លើ ប្រជាជនដូចមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន។ សេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ានក៏ឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរបស់អាស៊ាន ចំពោះធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស សេចក្ដីប្រកាសសិទ្ធិមនុស្សក្រុងវីយែននិង កម្មវិធីសកម្មភាព និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ដែលរដ្ឋសមាជិកអាស៊ានជាភាគីក៏ដូចជាសេចក្ដីប្រកាស អាស៊ានផ្សេងៗនិងលិខិតុបករណ៍ដែលទាក់ទងនឹងសិទ្ធិមនុស្ស។

ដោយសារសារៈសំខាន់នៃសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាននិងសេចក្តីថ្លែងការណ៍ភ្នំពេញ អាយឆាបានផ្តល់អាទិភាពក្នុងការផ្សព្វផ្សាយឯកសារទាំងនេះ រួមមាន ការបង្កើនការយល់ដឹងពីសារៈសំខាន់ និងការពាក់ព័ន្ធរបស់ឯកសារនេះ រៀបចំការបកប្រែជាភាសាជាតិនៃរដ្ឋសមាជិកអាស៊ាន និងការបង្ហោះការបកប្រែទៅគេហទំព័ររបស់អាយឆា(aichr.org)។ អាយឆាក៏បានពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នអាស៊ានតាមវិស័យលើលទ្ធភាពនៃការបង្កើតលិខិតុបករណ៍គតិយុត្តអាស៊ានស្តីពីសិទ្ធិមនុស្សដើម្បីអនុវត្តការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន។

ដើម្បីបង្កើនការយល់ដឹងពីសារៈសំខាន់នៃឯកសារទាំងនេះ អាយឆាសហការជាមួយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន បានរៀបចំព្រឹត្តិការណ៍រួមគ្នាក្រោមប្រធានបទ «ការរួមចំណែកក្នុងការកសាងសហគមន៍អាស៊ានតាមរយៈការអនុវត្តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន»។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងស្របគ្នានឹងការប្រារព្ធទិវាអាស៊ានលើកទី៤៦ នៅលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី។ នៅក្នុងព្រឹត្តិការណ៍នោះ អាយឆាក៏បានដាក់ចេញ «សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងការបកប្រែ» (សៀវភៅAHRD) ដែលមានការបកប្រែសេចក្តីប្រកាសអាស៊ានជាភាសាជាតិរបស់រដ្ឋសមាជិកអាស៊ាន។ ការដាក់ឱ្យប្រើប្រាស់ត្រូវបានកំណត់ជាមួយបទបង្ហាញសៀវភៅ AHRD ដល់តំណាងមកពីសមាជិកសភា អង្គការធុរកិច្ច ធនាគារខួរក្បាលនិងរាជបណ្ឌិត្យសភា អង្គការសង្គមស៊ីវិល និងថ្នាក់ដឹកនាំយុវជន។ ក្នុងអំឡុងពេលព្រឹត្តិការណ៍កិច្ចពិគ្រោះយោបល់ស្តីពី «សេចក្តីប្រកាសអាស៊ាន និងការកសាងសហគមន៍អាស៊ាននៅឆ្នាំ២០១៥» ក៏ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីតំណាងអាយឆា និងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន ជាវាគ្មិន។

**ទំនាក់ទំនងរបស់អាយឆាជាមួយបណ្តាភាគីខាងក្រៅ**

ចាប់តាំងពីពេលបង្កើត អាយឆាបានខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមានកិច្ចសហប្រតិបត្តិការជាស្ថាប័នជាមួយដៃគូខាងក្រៅនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ កិច្ចសន្ទនាជាមួយគណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស ភ្នាក់ងារសិទ្ធិជាមូលដ្ឋានតុលាការសិទ្ធិមនុស្សអឺរ៉ុប ភ្នាក់ងាររដ្ឋាភិបាលសហភាពអឺរ៉ុប ជប៉ុន និងសហរដ្ឋអាមេរិចក៏ដូចជាភ្នាក់ងារផ្សេងទៀត ឬតួអង្គនានារួមទាំងអង្គការសង្គមស៊ីវិលបានត្រួសត្រាយផ្លូវសម្រាប់អាយឆាដើម្បីបន្តសហការជាមួយភាគីពាក់ព័ន្ធ ផ្សេងទៀតនៅគ្រប់កម្រិតទាំងអស់។

អាយឆាបានធ្វើទស្សនកិច្ចសិក្សាមួយនៅសហរដ្ឋអាមេរិក នៅខែវិច្ឆិកា ឆ្នាំ២០១០ តបតាមការអញ្ជើញរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក ឯកឧត្តម បារ៉ាក់ អូបាម៉ា។ ទស្សនកិច្ចនេះបានផ្តល់ឱ្យអាយឆានូវឱកាសទាន់ពេលមួយដើម្បីជូនដំណឹងទៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ អង្គការអន្តរជាតិនិងអង្គការសង្គមស៊ីវិលអន្តរជាតិពីការងាររបស់អាយឆា តាំងតែពីការចាប់ផ្តើម ក៏ដូចជាកម្មវិធីនិងសកម្មភាពនានាដែលបានគ្រោងសម្រាប់ឆ្នាំខាងមុខ។ ដំណើរទស្សនកិច្ចនេះ បានបើកឱកាសឱ្យមានទស្សនៈផ្លាស់ប្តូរគ្នាលើបញ្ហាសិទ្ធិមនុស្សរួម និងស្វែងរកលទ្ធភាពនៃកិច្ចសហប្រតិបត្តិការនាពេលអនាគតជាមួយក្រសួងការបរទេសសហរដ្ឋអាមេរិក ភ្នាក់ងារអង្គការសហប្រជាជាតិពាក់ព័ន្ធ និងគណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្សនិងអង្គការសង្គមស៊ីវិល។

អាយឆា ក៏បានធ្វើទស្សនកិច្ចសិក្សាទៅអឺរ៉ុប នៅខែឧសភា ឆ្នាំ២០១១ តបតាមការអញ្ជើញរបស់អគ្គនាយកទំនាក់ទំនងខាងក្រៅរបស់គណៈកម្មការសហភាពអឺរ៉ុប។ អាយឆាបានធ្វើទស្សនៈកិច្ចនៅទីក្រុងអឺរ៉ុបចំនួនបីគឺទីក្រុងប្រ៊ុចសែល ទីក្រុងស្ត្រាសបើគ និងទីក្រុងវីយែន ហើយបានជួបជាមួយស្ថាប័នសហភាពអឺរ៉ុបផ្សេងៗពាក់ព័ន្ធសិទ្ធិមនុស្ស។ អាយឆាបានជួប

ជាមួយសេវាកម្មសកម្មភាពក្រៅអឺរ៉ុបរបស់សហភាពអឺរ៉ុប គណៈកម្មការអឺរ៉ុប និងផ្នែកពាក់ព័ន្ធផ្សេងៗនៃក្រុមប្រឹក្សាអឺរ៉ុប ភ្នាក់ងារសិទ្ធិមនុស្សមូលដ្ឋាន និងអង្គការដើម្បីសន្តិសុខនិងកិច្ចសហប្រតិបត្តិការក្នុងអឺរ៉ុប ជាពិសេសអង្គភាពដែលពាក់ព័ន្ធសេរីភាពសារព័ត៌មាន និងតំណាងពិសេសនិងអ្នកសម្របសម្រួលក្នុងការប្រឆាំងការជួញដូរនៅក្នុងសិទ្ធិមនុស្សនៃអង្គការដើម្បីសន្តិសុខនិងកិច្ចសហប្រតិបត្តិការក្នុងអឺរ៉ុប។ អាយឆាក៏បានជួបជាមួយអង្គការសង្គមស៊ីវិលអឺរ៉ុបនានាទៀត និងបានផ្លាស់ប្តូរព័ត៌មានពីសកម្មភាពមួយចំនួន។

ដំណើរទស្សនកិច្ចលើកទី២ទៅកាន់សហភាពអឺរ៉ុបត្រូវបានធ្វើឡើង នៅខែតុលា ឆ្នាំ២០១៥ ។ អាយឆារួមជាមួយប្រធាន ACWC ACW និង ACMW បានចូលរួមក្នុងកិច្ចសន្ទនាគោលនយោបាយអាស៊ាន - សហភាពអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ នេះគឺជាការសន្ទនាគោលនយោបាយលើកដំបូងបំផុតស្តីពីសិទ្ធិមនុស្សរវាងអាស៊ាននិងសហភាពអឺរ៉ុប។ ក្នុងអំឡុងកិច្ចសន្ទនាគោលនយោបាយ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនទានប្រកបដោយការបើកចំហនិងស្តាបនាលើបញ្ហាសិទ្ធិមនុស្សរួមនិងលើការអភិវឌ្ឍសិទ្ធិមនុស្សនាពេលថ្មីៗនេះនៅក្នុងសហភាពអឺរ៉ុបនិងអាស៊ាន ហើយបានកំណត់នូវវិស័យសក្តានុពលនៃកិច្ចសហប្រតិបត្តិការសិទ្ធិមនុស្ស។ គណៈប្រតិភូអាស៊ានបានជួបជាមួយសមាជិកនៃសភាអឺរ៉ុប បណ្តាញអង្គការមិនមែនរដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យដែលមានមូលដ្ឋាននៅទីក្រុងប្រ៊ុសែល ។ ពួកគេក៏បានជួបជាមួយធុរជនអឺរ៉ុបជាច្រើននៅតុមូលដែលរៀបចំដោយ The Shift និង CSR អឺរ៉ុប។ ពួកគេបានចូលរួមសិក្ខាសាលាមួយស្តីពី «យន្តការសិទ្ធិមនុស្សប៉ានអឺរ៉ុប» ដែលរៀបចំឡើងដោយក្រសួងការបរទេសប៊ែលហ្សិកដោយមានការចូលរួមពីតំណាងរបស់ក្រុមប្រឹក្សាអឺរ៉ុប និងអង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការក្នុងអឺរ៉ុប។ គណៈប្រតិភូក៏បានទស្សនកិច្ចស្ថាប័នប៊ែលហ្សិកជាច្រើនដែលទាក់ទងនឹងជនអន្តោប្រវេសន៍ជនពិការនិងឱកាសស្មើៗគ្នា។

អាយឆាត្រូវបានអញ្ជើញទៅប្រទេសជប៉ុនក្នុងឆ្នាំ២០១៤ ដើម្បីធ្វើទស្សនកិច្ចសិក្សាមួយដែលពួកគេបានជួបជាមួយគូសន្ទនាសំខាន់ៗមួយចំនួន។ អាយឆា បានជួបជាមួយអនុរដ្ឋមន្ត្រីសភាជាន់ខ្ពស់សម្រាប់កិច្ចការអន្តរជាតិ អនុរដ្ឋមន្ត្រីសម្រាប់គោលនយោបាយការបរទេស និងអនុប្រធានខុទ្ទកាល័យលេខាធិការ ឬអគ្គរដ្ឋលេខាធិការនៃលេខាធិការដ្ឋានសន្តិសុខជាតិ។ អាយឆាក៏បានជួបជាមួយអ្នកជំនាញសិទ្ធិមនុស្សពីប្រទេសជប៉ុនដូចជាលោកបណ្ឌិតយ៉ូស៊ូ យោកូតា ( Yozo Yokota ) ដែលជាប្រធានមជ្ឈមណ្ឌលសិទ្ធការអប់រំ និងសិទ្ធិមនុស្សនិងបណ្តុះបណ្តាល និងជាសមាជិកនៃអនុគណៈកម្មាធិការអង្គការសហប្រជាជាតិ ស្តីពីការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស ឯកអគ្គរដ្ឋទូតទទួលបន្ទុកកិច្ចការអង្គការសហប្រជាជាតិនាយកវិទ្យាស្ថានស្រាវជ្រាវសិទ្ធិមនុស្សក្យូតូក្នុងចំណោមវិទ្យាស្ថានដទៃទៀត។ អាយឆាក៏បានសង្កេតមើលឧទាហរណ៍នៃការងាររបស់ជនមានពិការភាពរបស់ប្រទេសជប៉ុននៅក្រុមហ៊ុនអ៊ីតថេន មែនស៊ូស៊ី សូលៃ។

នៅឆ្នាំ២០១៤ អាយឆាបានសហការរៀបចំសកម្មភាពនិងសិក្ខាសាលាមួយចំនួនជាមួយដៃគូខាងក្រៅផ្សេងៗ ដែលពាក់ព័ន្ធជាមួយនឹងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សដូចជា អង្គការសហប្រជាជាតិសម្រាប់ស្ត្រី កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ មូលនិធិប្រជាជននៃអង្គការសហប្រជាជាតិ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន សហភាពអឺរ៉ុប និងក្រុមការងារសម្រាប់យន្តការសិទ្ធិមនុស្សអាស៊ាន។

អាយឆាក៏បានជួបជាមួយលោកស្រី ណាវ៉ាន់ធេម ពីឡាយ ( Navanethem Pillay ) ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកិច្ចប្រជុំលើកទី៧ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី នៅខែវិច្ឆិកា ឆ្នាំ២០១១ និងតំណាងសហភាពអឺរ៉ុបពិសេសទទួលបន្ទុកសិទ្ធិមនុស្ស លោក ស្តាវ៉ស់ ឡាំប្រីនីឌីស (Stavros Lambrinidis) នៅកិច្ចប្រជុំលើកទី១២ ខែឧសភា ឆ្នាំ២០១៣ នៅលេខាធិការដ្ឋានអាស៊ាន។

អាយឆាបានធ្វើទំនាក់ទំនងជាមួយបណ្តាអង្គការសង្គមស៊ីវិលក្នុងព្រឹត្តិការណ៍មួយចំនួន ជាពិសេសនៅកិច្ចពិគ្រោះយោបល់ក្នុងកំឡុងពេលព្រាងសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងកិច្ចពិគ្រោះយោបល់មានគោលបំណងរួមចំណែកក្នុងការពិនិត្យឡើងវិញនៃលក្ខន្តិកៈរបស់អាយឆា។ ឆ្នាំ២០១៥គឺបានគូសបញ្ជាក់ពីការអភិវឌ្ឍគួរឱ្យកត់សម្គាល់លើអន្តរទំនាក់ទំនងរវាងអាយឆានិងបណ្តាអង្គការសង្គមស៊ីវិល ដោយការអនុម័តគោលការណ៍ណែនាំស្តីពីទំនាក់ទំនងអាយឆាជាមួយនឹងអង្គការសង្គមស៊ីវិល។ គោលការណ៍នេះចែងអំពីប្រភេទនិងបែបបទនៃទំនាក់ទំនង ហើយទាំងនេះនឹងបង្កើតបន្ថែមទំនាក់ទំនងរវាងអាយឆានិងអង្គការសង្គមស៊ីវិល។

អាយឆានឹងបន្តការប្រតិបត្តិគោលការណ៍ទាំងនេះជាទៀងទាត់ សម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាននៅក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។ បញ្ជីឈ្មោះអង្គការសង្គមស៊ីវិលដែលទទួលបានទំនាក់ទំនងពិគ្រោះយោបល់ជាមួយអាយឆាគឺមាននៅគេហទំព័រ aichr.org ។

## ការអភិវឌ្ឍចាប់តាំងពីការបង្កើតសហគមន៍អាស៊ាន

ចាប់តាំងពីពេលបង្កើតនៅឆ្នាំ២០០៩ អាយឆាមានភាពរឹងមាំក្នុងការអភិវឌ្ឍយុទ្ធសាស្រ្តសម្រាប់ការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដើម្បីបំពេញបន្ថែមដល់ការកសាងសហគមន៍អាស៊ានប្រកបដោយបរិយាប័ន្ន យកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាស្នូល។ ទោះបីជាយន្តការសិទ្ធិមនុស្សដែលទើបបង្កើតឡើងនៅខ្ចីជាងគេក្តី ក៏ត្រូវបានមើលឃើញនូវសមិទ្ធផលគួរឱ្យកត់សំគាល់ ក្នុងការជំរុញសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ាន។ ការអនុវត្តកម្មវិធីរបស់អាយឆា បានផ្លាស់ប្តូរពីសកម្មភាពមួយៗទៅជាសកម្មភាពជាប្រចាំចាប់តាំងពីចុងឆ្នាំ២០១៥ ដូចជាការអភិវឌ្ឍលិខិតុបករណ៍ច្បាប់សិទ្ធិមនុស្សអាស៊ាននិងលើអន្តរផ្នែករវាងសិទ្ធិមនុស្សបរិស្ថាននិងការប្រែប្រួលអាកាសធាតុ។

អាយឆាក៏បានពង្រីកអាទិភាពរបស់ខ្លួន ដើម្បីបញ្ចូលប្រធានបទនិងក្រុមគោលដៅថ្មីៗ ដូចជាសិទ្ធិទទួលបានសន្តិភាព សិទ្ធិទទួលបានការអប់រំ ទំនួលខុសត្រូវសង្គមសាជីវកម្មធំៗនិងសិទ្ធិមនុស្ស និងសារព័ត៌មាននិងសិទ្ធិមនុស្ស។ នៅខែមីនាឆ្នាំ២០១៧ អាយឆាបានផ្តួចផ្តើមទំនាក់ទំនងលើកដំបូងរបស់ខ្លួនជាមួយនឹងយុត្តាធិការរបស់រដ្ឋសមាជិកអាស៊ានតាមរយៈសន្និសីទយុត្តាធិការអាយឆាស្តីពីការចែករំលែកឧត្តមានុវត្តន៍ពាក់ព័ន្ធនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

កិច្ចសហប្រតិបត្តិការអន្តរវិស័យ និងអន្តរសសរស្តម្ភនានាត្រូវបានអនុវត្តដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានបញ្ជ្រាបនៅគ្រប់សសរស្តម្ភទាំងបីរបស់អាស៊ាន។ កិច្ចពិគ្រោះយោបល់លើកដំបូង អាយឆា-សមធីស៊ី(AICHR-SOMTC) ស្តីពីវិធីសាស្រ្តផ្អែកលើសិទ្ធិមនុស្ស ក្នុងការអនុវត្តអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្រ្តីនិងកុមារ ដែលប្រារព្ធឡើងនៅខែកញ្ញា ឆ្នាំ២០១៦ ហើយកិច្ចពិគ្រោះយោបល់លើកទីពីរគ្រោងនឹងប្រជុំនៅឆ្នាំ២០១៧ ។

សិទ្ធិរបស់ជនមានពិការភាពក៏ជាអាទិភាពមួយទៀតរបស់អាយឆាផងដែរ។ អាយឆាសហការជាមួយកិច្ចប្រជុំឧត្តមមន្រ្តីស្តីពីសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍ និងគណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់និងការការពារសិទ្ធិស្រ្តី និងកុមារ បានបង្កើតក្រុមការងារស្តីពីការបញ្ជ្រាបសិទ្ធិជនមានពិការភាពនៅក្នុងសហគមន៍អាស៊ាន ដោយមានអាណត្តិក្នុងការព្រាងផែនការសកម្មភាពតំបន់ស្តីពីពិការភាព។ នេះបង្ហាញពីកិច្ចសហការដំបូងបង្អស់រវាងសសរស្តម្ភសហគមន៍នយោបាយ-សន្តិសុខអាស៊ាន និងសហគមន៍សង្គមវប្បធម៌អាស៊ានស្តីពីពិការភាព។

សកម្មភាពខាងក្រោមនេះនឹងត្រូវបានរៀបចំដោយអាយឆា ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៥០អាស៊ានរួមមាន៖

- ការដាក់ចេញនូវផែនការសកម្មភាពតំបន់ស្តីពីការបញ្ជ្រាបសិទ្ធិជនមានពិការភាពក្នុងសហគមន៍អាស៊ាន។

- ការតស៊ូមតិយុវជនរបស់អាយឆាស្តីពីសិទ្ធិមនុស្សឆ្នាំ២០១៧ - ខួបអនុស្សាវរីយ៍លើកទី៥០៖ ដំណើរឆ្ពោះទៅរកសហគមន៍មួយដែលមាននិរន្តភាព។

វីដេអូអាយឆា និងការចងក្រងពិពណ៌នានៃឯកសារស្នូលរបស់អាយឆារួមមាន៖ (១) កូនសៀវភៅ អាយឆា៖ អ្វីដែលអ្នកត្រូវដឹង (២) សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាននិងសេចក្តីថ្លែងការណ៍ភ្នំពេញស្តីពីការអនុម័តលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និង (៣) លក្ខន្តិកអាយឆា ក៏នឹងត្រូវផ្សព្វផ្សាយផងដែរនៅក្នុងការរំលឹកខួបអនុស្សាវរីយ៍អាស៊ាន។

| AICHR ACTIVITIES |
|---|

## សកម្មភាពអាយឆា



សិក្ខាសាលាបណ្តុះបណ្តាលរបស់អាយឆា-ACWC លើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ថ្ងៃទី១៣-១៤ ខែកក្កដា ឆ្នាំ២០១៧ នៅប្រទេសសិង្ហបុរី។



*សន្និសីទយុត្តាធិការរបស់អាយឆាស្តីពីការចែករំលែកឧត្តមានុវត្តទាក់ទងនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ថ្ងៃទី១៣-១៥ ខែមីនា ឆ្នាំ២០១៧ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។*



*សិក្ខាសាលាអាយឆាថ្នាក់តំបន់ស្តីពីការពង្រឹងផែនការសកម្មភាពជាតិស្តីពីការជួញដូរមនុស្សដើម្បីធានានូវការអនុវត្តមានប្រសិទ្ធភាពនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ និងផែនការសកម្មភាពអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ ថ្ងៃទី១-២ ខែធ្នូ ឆ្នាំ២០១៦ រាជធានីភ្នំពេញ ប្រទេសកម្ពុជា*




*សិក្ខាសាលាអាយធាស្តីពីការលើកកម្ពស់ការទទួលខុសត្រូវសង្គមរបស់សាជីវកម្មធំៗ  និងសិទ្ធិមនុស្សក្នុងអាស៊ាន ថ្ងៃទី៣-៤ ខែវិច្ឆិការ ឆ្នាំ ២០១៦ នៅប្រទេសសិង្ហបុរី*



*សិក្ខាសាលាអាយធាស្តីពីយុទ្ធសាស្ត្រទាក់ទងប្រកបដោយប្រសិទ្ធភាពដើម្បីប្រយុទ្ធការជួញដូរមនុស្ស ថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០១៦ នៅទីក្រុងញ៉ាចាង ប្រទេសវៀតណាម*



*ការតស៊ូមតិយុវជនរបស់អាយធាស្តីពីសិទ្ធិមនុស្ស ថ្ងៃទី៥-៦ ខែកញ្ញា ឆ្នាំ២០១៥ ប្រទេសសិង្ហបុរី*



*កម្មវិធីអាយធាស្តីពីសិទ្ធិមនុស្ស៖ ការបណ្តុះបណ្តាលជនបង្គោលសម្រាប់អ្នកកាសែតក្នុងរដ្ឋសមាជិកអាស៊ាន ថ្ងៃទី២៥-២៩ ខែកក្កដា ឆ្នាំ២០១៥ នៅក្រុងបាងកក ប្រទេសថៃ*

## សំនួរដែលសួរជាញឹកញាប់

**១. តើអន្តររដ្ឋាភិបាលមានន័យយ៉ាងដូចម្តេច ?**

ចំ. អន្តររដ្ឋាភិបាល មានន័យថា អង្គការមួយត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរដ្ឋប្រជាជាតិ។ សមាជិកអង្គការនេះមានសមាសភាពពីរដ្ឋអធិបតេយ្យ (សំដៅទៅរដ្ឋសមាជិក)។

**២. ហេតុអ្វីបានជាសមាជិកអាយឆា សំដៅទៅលើតំណាង ហើយមិនមែនឧត្តមស្នងការទៅវិញ ?**

ចំ. សមាជិកអាយឆា គឺជាតំណាងរបស់រដ្ឋសមាជិកអាស៊ាន ដែលទទួលបន្ទុកពីរដ្ឋាភិបាលរៀងខ្លួន ដែលត្រូវបានតែងតាំងដោយមានអណត្តិពេញលេញ ជាមួយការគោរពលើគោលការណ៍ធម្មនុញ្ញអាស៊ាន លក្ខន្តិកៈ ស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ ហើយមានទំនួលខុសត្រូវលើកកម្ពស់និងការការពារសិទ្ធមនុស្ស និងសេរីភាពជាមូលដ្ឋានប្រជាជនអាស៊ាន។

**៣. តើកាតព្វកិច្ចរបស់អាយឆា មានអ្វីខ្លះ ?**

ចំ. លក្ខន្តិកៈរបស់អាយឆាចែងពីអាណត្តិរបស់អាយឆាមានចំនួន១៤។ អាយឆា គឺជាអង្គភាពចម្បងរបស់អាស៊ាន និងជាស្ថាប័នគ្របដណ្តប់លើសិទ្ធិមនុស្សជាមួយនឹងទំនួលខុសត្រូវក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ាន។ អាយឆា ដែលជាស្ថាប័នគ្របដណ្តប់លើសិទ្ធិមនុស្សអាស៊ាន ត្រូវធ្វើការជាមួយស្ថាប័នអាស៊ានដទៃទៀតដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដើម្បីស្របជាមួយរបស់អាយឆា ក៏ដូចជាស្ថាប័នអាស៊ានដទៃទៀតលើបណ្តាវិស័យរួម។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអាស៊ាន និងជាមួយដៃគូខាងក្រៅ អាយឆានឹងបង្កើតកិច្ចសហប្រតិបត្តិការតំបន់ទៅលើសិទ្ធិមនុស្ស។

**៤. អាយឆា ជារឿយៗប្រើពាក្យថា «គ្របដណ្តប់» នៅពេលដែលអធិប្បាយពីអណត្តិរបស់អាយឆា។ តើវាមានន័យយ៉ាងដូចម្តេច ?**

ចំ.ទោះបីជាមានស្ថាប័នអាស៊ានដទៃទៀតដែលធ្វើការពាក់ព័ន្ធនឹងសិទ្ធិមនុស្ស  ដូចជាអ្នកជំនាញលើបញ្ហាសិទ្ធិស្ត្រីនិងកុមារ ឬទេសន្តរប្រវេសន៍ អាយឆាមានទំនួលខុសត្រូវទាំងមូលក្នុងអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។ អាយឆា ក៏ធ្វើការទាក់ទងទៅនឹងសិទ្ធិមនុស្សគ្រប់ជំពូកផងដែរដូចជាសិទ្ធិនយោបាយ ពលរដ្ឋ សេដ្ឋកិច្ច សង្គម និងវប្បធម៌ រួមទាំងក្រុមសិទ្ធិផ្សេងៗទៀតផងដែរ។

**៥. តើអាយឆាធ្វើការជាមួយអង្គភាពដទៃទៀតដោយរបៀបណា ដូចជាអង្គការសង្គមស៊ីវិល អង្គការមិនរដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ និងអង្គការសិទ្ធមនុស្សដទៃទៀត និងអង្គការសហប្រជាជាតិ ស្ថាប័នតាមវិស័យថ្នាក់តំបន់ ក៏ដូចជាវិស័យឯកជន ?**

ចំ. អាយឆាដែលជាស្ថាប័នពិគ្រោះយោបល់ ត្រូវធ្វើការពិគ្រោះយោបល់និងសហការជាមួយអង្គភាពដទៃ ប្រសិនបើសមស្រប។ អាយឆា ត្រូវការធ្វើបរិវិសកម្មវិធីសម្រាប់ការទាក់ទងជាមួយអង្គការ ឬអង្គភាពប្រភេទផ្សេងៗគ្នា។

**6. ប្រសិនបើសិទ្ធិរបស់ខ្ញុំត្រូវបានរំលោភបំពាន តើខ្ញុំអាចដាក់ពាក្យបណ្តឹងទៅកាន់អាយឆា ឬតំណាងអាយឆាប្រចាំប្រទេសខ្ញុំបានដែរឬទេ ? តើសាធារណៈជនប្រាស្រ័យទាក់ទងជាមួយអាយឆាបានយ៉ាងដូចម្តេច ?**

ចំ. អាយឆាដែលជាអង្គការអន្តររដ្ឋាភិបាល ផ្តោតលើការងារកិច្ចសហប្រតិបត្តិការតំបន់លើការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ នៅក្នុងលក្ខន្តិកបច្ចុប្បន្ន ដែលបានអនុម័តនៅខែកក្កដា ឆ្នាំ២០០៩ ដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន អាយឆាមិនមានអាណត្តិក្នុងការដោះស្រាយករណីរបស់បុគ្គលនោះទេ។ អង្គការ ឬបុគ្គលត្រូវធ្វើលិខិតជូនដំណឹងទៅអាយឆា តាមរយៈប្រធានអាយឆា និងចតចម្លងជូនតំណាងអាយឆាដទៃទៀត និងលេខាធិការដ្ឋានអាស៊ាន។



*The AICHR's meeting with the Secretary-General of ASEAN*

## ៧.តើការងាររបស់អាយឆារួមចំណែក ឬបង្កើតឥទ្ធិពលដល់សិទ្ធិមនុស្សនៅក្នុងតំបន់ និងសិទ្ធិមនុស្សរបស់ប្រជាជននៅក្នុងតំបន់អាស៊ីអាគ្នេយ៍កម្រិតណា?

ចំ.ឥទ្ធិពលទៅលើសិទ្ធិមនុស្សអាចកើតមានឡើងតាមរយៈការបង្កើតការយល់ដឹងដល់ប្រជាពលរដ្ឋអាស៊ានពីសិទ្ធិរបស់ពួកគេ។ លើសពីនេះទៀត វិធីសាស្ត្រជាប្រព័ន្ធនៃការសិក្សាតាមប្រធានបទជាមួយនឹងការផ្តល់លទ្ធផលទៅសាធារណជនច្បាស់នឹងបង្កើតឥទ្ធិពលដល់សិទ្ធិមនុស្សជាមិនខាន។ របាយការណ៍ប្រចាំឆ្នាំរបស់អាឆាដែលបានដាក់បង្ហាញជូនទៅរដ្ឋមន្ត្រីការបរទេសជាមួយការបញ្ចេញមតិដោយអាឆា បូករួមនឹងព័ត៌មានជាសាធារណៈពីការងារអាយឆា ពិតជាអាចបង្កើតឥទ្ធិពលទៅលើសិទ្ធិមនុស្ស។

## ៨. អាយឆាហាក់ដូចជាផ្តោតសំខាន់លើការលើកកម្ពស់ជាជាងការការពារសិទ្ធិមនុស្ស តើវាពិតដែរឬទេ?

ចំ. អាយឆាធ្វើការក្រោមស្មារតីនៃការពិគ្រោះយោបល់និងកង់សង់ស៊ីស។ ទោះបីជាយ៉ាងណាក៏ដោយ ស្មារតីនេះមិនមែនជាឧបសគ្គដល់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សទេ ជាពិសេសលើការអប់រំនិងការបង្កើនការយល់ដឹងអំពីសិទ្ធិមនុស្សដល់ប្រជាជនអាស៊ាន។ ការលើកកម្ពស់សិទ្ធិមនុស្ស គួរតែត្រូវធ្វើឡើងស្របជាមួយនឹងការអភិវឌ្ឍផ្សេងទៀតដើម្បីធានាថាយន្តការការពាររឹងមាំនេះត្រូវបានបង្កើត។

## ៩.តើអគ្គលេខាធិការអាស៊ាននិងលេខាធិការដ្ឋានអាស៊ានមានតួនាទីអ្វីខ្លះ?

ចំ. អគ្គលេខាធិការអាស៊ានអាចលើកឡើងពីបញ្ហាពាក់ព័ន្ធមកកាន់អាយឆា ដែលជាការអនុវត្តកាតព្វកិច្ចនិងទំនួលខុសត្រូវរបស់ខ្លួនស្របតាមបញ្ញត្តិធម្មនុញ្ញអាស៊ាន។ អគ្គលេខាធិការ ក៏អាចលើកឡើងពីបញ្ហាទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនិងសេចក្តីសម្រេចរបស់អាស៊ានផងដែរ។ លេខាធិការដ្ឋានអាស៊ានបច្ចុប្បន្នបម្រើការងារជាលេខាធិការរបស់អាយឆា។ លេខាធិការដ្ឋានអាស៊ាន រក្សានូវទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាងអាយឆាជាមួយបណ្តាស្ថាប័នអាស៊ាន ភាគីខាងក្រៅ និងភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងផ្សព្វផ្សាយព័ត៌មានពីការអភិវឌ្ឍចុងក្រោយបំផុតរបស់អាស៊ាននិងអាយឆាទៅឱ្យភាគីពាក់ព័ន្ធផងដែរ។ លេខាធិការដ្ឋានអាស៊ាន គឺជាស្ថាប័នរក្សាមូលនិធិរបស់អាយឆា ហើយក៏ជាស្ថាប័នអង្គចងចាំរបស់អាស៊ាននិងរបស់អាយឆាផងដែរ។ លេខាធិការដ្ឋានអាស៊ាន គាំទ្រការអនុវត្តកម្មវិធីឬសកម្មភាពអាទិភាពរបស់អាយឆា ព្រមទាំងស្នើវាយតម្លៃ និងជួយក្នុងការរៀបចំនិងការអនុវត្តគម្រោង ផែនការការងាររបស់អាយឆា។

## ១០ .តើខ្ញុំអាចរកព័ត៌មានបន្ថែមពីអាយឆានៅទីណាបាន?

ចំ. ព័ត៌មានទូទៅ និងព័ត៌មានថ្មីៗពីអាស៊ាន រួមទាំងសេចក្តីប្រកាសព័ត៌មានរបស់អាយឆា អាចចូលមើលបានតាមរយៈគេហទំព័រ asean.org។ អាយឆាក៏មានគេហទំព័រតំបន់ផ្ទាល់ខ្លួនផងដែរ នោះគឺ aichr.org។

តំណាងអាយធា ត្រូវបានជ្រើសរើស និងតែងតាំងដោយរដ្ឋាភិបាលរៀងៗខ្លួនជាមួយនឹងការពិចារណាទៅលើសមភាពយេនឌ័រ សុចរិតភាព និងសមត្ថភាពនៅក្នុងវិស័យសិទ្ធិមនុស្ស។ តំណាងអាយធា មានអណត្តិធ្វើការចំនួន៣ឆ្នាំ និងអាចត្រូវបានតែងតាំងចំនួនមួយអណត្តិទៀត។

| តំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ២០១៦-២០១៨ |
|---|



## ប្រ៊ុយណេដារូសាឡឹម

ឯកឧត្តម ហាជី ណាហ្សមី ប៊ីន ហាជី មហាម៉ាត់ H.E.Haji Nazmi Bin Haji Mohamad



## កម្រិតវប្បធម៌

- បរិញ្ញាបត្រផ្នែកគ្រប់គ្រង នៃសាកលវិទ្យាល័យប្រ៊ុយណេដារូសាឡឹម

## បទពិសោធន៍ការងារ

- ២០១៧៖ តំណាងប្រ៊ុយណេដារូសាឡឹមប្រចាំអាយធា
- ២០១៧៖ លេខាធិការអចិន្ត្រៃយ៍(កិច្ចការសាជីវកម្ម និងរដ្ឋបាលសាធារណៈ) នៃការិយាល័យនាយករដ្ឋមន្ត្រី
- ២០១៤៖ សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ចប្រ៊ុយណេ
- ២០១២៖ លេខាធិការអចិន្ត្រៃយ៍(ផ្នែកគ្រប់គ្រង និងអន្តរជាតិ) នៃក្រសួងហិរញ្ញវត្ថុ
- ២០១២៖ អនុប្រធានមជ្ឈមណ្ឌលសិក្សាយុត្តសាស្ត្រ និងគោលនយោបាយ
- ២០១២៖ អនុសហប្រធានមូលនិធិនយោជិក
- ២០១២៖ ប្រធានសាជីវកម្មការពារប្រាក់បញ្ញើប្រ៊ុយណេដារូសាឡឹម
- ២០១២៖ ប្រធានក្រុមប្រឹក្សាអធិការកិច្ចហិរញ្ញវត្ថុអ៊ីស្លាម
- ២០១២៖ ទេសាភិបាលជំនួសនៃធនាគារអភិវឌ្ឍអាស៊ី(ADB)
- ២០០៨៖ អនុប្រធានលេខាធិការអចិន្ត្រៃយ៍ នៃក្រសួងការបរទេស និងពាណិជ្ជកម្ម
- ២០០៨៖ ប្រធាននាយកដ្ឋានចំណាយនៃក្រសួងហិរញ្ញវត្ថុ

- ២០០៧៖ ទីប្រឹក្សានាយកប្រតិបត្តិប្រចាំអាស៊ីអាគ្នេយ៍ ក្រុមបោះឆ្នោតអាស៊ី នៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)
- ២០០៤៖ មន្ត្រីរដ្ឋបាលនៃក្រសួងហិរញ្ញវត្ថុ
- ២០០០៖ មន្ត្រីរដ្ឋបាលនៃក្រសួងឧស្សាហកម្មនិងធនធានមនុស្សថ្នាក់បឋម
- ១៩៩៧៖ សមាជិកលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ចប្រ៊ុយណេដារូសាឡឹម
- ១៩៩៦៖ មន្ត្រីរដ្ឋបាលនៃការិយាល័យនាយករដ្ឋមន្ត្រី
- ១៩៩៥៖ មន្ត្រីរដ្ឋបាលក្រសួងហិរញ្ញវត្ថុ
- ១៩៩១៖ មន្ត្រីគម្រោងក្រសួងឧស្សាហកម្ម និងធនធានមនុស្សថ្នាក់បឋម។



## ប្រទេសកម្ពុជា

លោកជំទាវ ហ៊ាន ប៉ូលីណេ H.E. Mrs. Hean Polyne




## កម្រិតវប្បធម៌

- អនុបណ្ឌិតផ្នែកលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ច នៃសាកលវិទ្យាល័យចចថោន សហរដ្ឋអាមេរិក
- អនុបណ្ឌិតផ្នែកសិក្សាអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យអ៊ិស អង់លៀរ ចក្រភពអង់គ្លេស
- បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា
- បរិញ្ញាបត្រផ្នែកTEFL នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា

## បទពិសោធន៍ការងារ

- តំណាងកម្ពុជាប្រចាំ អាយធា
- ប្រធាននាយកដ្ឋានអាស៊ាន នៃទីស្តីការគណៈរដ្ឋមន្ត្រី
- សមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុន iAB Group
- អនុប្រធាន ក្រុមហ៊ុន iAB ស្ថាបត្យកម្ម និងសំណង់
- ជនបង្គោលទីស្តីការគណៈរដ្ឋមន្ត្រី នៃគណៈកម្មការជាតិនិហិតដ្ឋានពាក់ព័ន្ធពាណិជ្ជកម្ម និងវិធានការមិនមែនពន្ធគយ
- សមាជិកគណៈកម្មាធិជាតិប្រឆាំងការជួញដូរមនុស្ស
- សមាជិក ក្រុមស្រាវជ្រាវទំនាក់ទំនងកម្ពុជា-ចិន



## ប្រទេសឥណ្ឌូនេស៊ី

លោកជំទាវ បណ្ឌិត ឌីណា វិណ្ណុ H.E. Mrs. Dinna Wisnu




## កម្រិតវប្បធម៌

- បណ្ឌិត ( ខាងទស្សនវិជ្ជា ) ផ្នែកវិទ្យាសាស្ត្រនយោបាយ នៃសាកលវិទ្យាល័យរដ្ឋអូហៃអូ សហរដ្ឋអាមេរិក-ដោយអាហាររូបករណ៍ពេញថ្លៃ
- អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ នៃសាកលវិទ្យាល័យរដ្ឋអូហៃអូ សហរដ្ឋអាមេរិក-ដោយអាហាររូបករណ៍ពេញថ្លៃ
- បរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ នៃសាកលឥណ្ឌូនេស៊ី ទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី

## បទពិសោធន៍ការងារ

- ២០១៧-បច្ចុប្បន្នះ សហស្ថាបនិក និងនាយកវិទ្យាស្ថានគោលនយោបាយសាធារណៈ អាត្មាជ័យ
- ២០១៥ះ សហស្ថាបនិក និងសមាជិកមជ្ឈមណ្ឌលគាំពារសង្គម និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ ក្នុងកម្មវិធីគាំពារសង្គម នៃសាកលវិទ្យាល័យឥណ្ឌូនេស៊ី
- ២០០៩-បច្ចុប្បន្នះ ផ្តល់ប្រឹក្សាដល់រដ្ឋាភិបាលឥណ្ឌូនេស៊ី និងចូលរួមសកម្មភាពសេដ្ឋកិច្ចនយោបាយ និងសកម្មភាពទំនាក់ទំនងការទូត
- ខែកញ្ញា ២០០៨-២០១៧ះ សហស្ថាបនិក និងនាយកសាលាឧត្តមសិក្សាទំនាក់ទំនងការទូតប៉ារ៉ាម៉ាឌីណា
- ២០០៧-២០០៨ះ ប្រធានស្រាវជ្រាវ មជ្ឈមណ្ឌលសម្រាប់ការសិក្សាសហប្រតិបត្តិការអាស៊ីខាងកើត នៃសាកលវិទ្យាល័យឥណ្ឌូនេស៊ី
- ២០០៧-២០០៨ះ នាយករង និងអ្នកជំនាញសង្គមស៊ីវិល និងគម្រោង RESPECT លើសាសនា និងសង្គមពហុនិយម សមធម៌ និងការអត់ធ្មត់ ( World Learning and USAID )
- ២០០១-២០០៧ះ សហាការីបង្រៀន នៃនាយកដ្ឋានវិទ្យាសាស្ត្រនយោបាយ នៃរដ្ឋអូហៃអូ សហរដ្ឋអាមេរិក
- ១៩៩៨-២០០១ះ វិទ្យាស្ថានប្រជាធិបតេយ្យជាតិ
- ១៩៩៦-១៩៩៨ះ កាសែតប្រចាំសប្តាហ៍ ស៊ូអារ៉ា កាយ៉ា រីកលី



## សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម ភូខង ស៊ីសូឡាត  H.E. Mr. Phoukhong Sisoulath




### កម្រិតវប្បធម៌

- អនុបណ្ឌិតផ្នែកច្បាប់អន្តរជាតិ នៃវិទ្យាស្ថានជាតិមូស្គូទំនាក់ទំនងអន្តរជាតិ ប្រទេសរុស្សី
- ថ្នាក់ក្រោយឧត្តមសិក្សាផ្នែកច្បាប់អន្តរជាតិ នៃសាកលវិទ្យាល័យណតទីងហេម ចក្រភពអង់គ្លេស
- សញ្ញាបត្រជាន់ខ្ពស់ផ្នែកនយោបាយនិងរដ្ឋបាលសាធារណៈ ប្រទេសឡាវ
- អតីតនិស្សិតវិទ្យាស្ថានសិក្សាហ្វូលប្រាយអាមេរិកៈ កំណែទម្រង់ក្នុងប្រវិត្តិសាស្រអាមេរិកនិងនីតិសាស្ត្រ នៃមហាវិទ្យាល័យបូស្តុន សហរដ្ឋអាមេរិក

### បទពិសោធន៍ការងារ

- ២០១៥ ៖ សមាជិកគណៈប្រតិភូឡាវប្រចាំ អង្គភាពរបាយការណ៍ត្រួតពិនិត្យឡើងវិញតាមកំណត់ជាសកលលើកទី នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។
- ចាប់ពី២០១៤៖ ប្រធានផ្តល់ទិន្នន័យយទី៥ ៖ ច្បាប់អន្តរជាតិ និងសិទ្ធមនុស្ស ផែនការមេរឺផ្នែកច្បាប់ស្តីពីនីតិរដ្ឋ
- ចាប់ពី២០១៤៖ ប្រធានលេខាធិការដ្ឋាន នៃគណកម្មាធិការអចិន្ត្រៃយ៍សិទ្ធមនុស្សថ្នាក់ជាតិប្រទេសឡាវ
- ចាប់ពី២០១៤៖ អគ្គនាយកនៃនាយកដ្ឋានសន្ធិសញ្ញា និងនីតិសាស្ត្រ នៃក្រសួងការបរទេស
- ២០១៤៖ សិក្ខាកាម នៃកម្មវិធីកម្មវិធីទស្សនៈកិច្ចសហភាពអឺរ៉ុប
- ចាប់ពី២០១៣ ៖ តំណាងប្រទេសឡាវប្រចាំអាយធា
- ២០១១-២០១២៖ ជំនួយការតំណាងប្រទេសឡាវប្រចាំអាយធា បន្ទាប់មកជា តំណាងប្រទេសឡាវប្រចាំអាយធាបម្រុង
- ១៩៩៦-២០១០៖ ចូលរួមនាយកដ្ឋានសន្ធិសញ្ញា និងនីតិសាស្ត្រ នៃក្រសួងការបរទេស ជាមន្ត្រីការិយាល័យ មន្ត្រីនីតិសាស្ត្រ មន្ត្រីសិទ្ធមនុស្ស អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានការងារនីតិសាស្ត្រ ប្រធាននាយកដ្ឋានសិទ្ធិមនុស្ស អគ្គនាយករង ប្រធានគម្រោងថ្នាក់ជាតិនៃគម្រោងនីតិសាស្ត្រអន្តរជាតិតំណាក់កាលទី១ ទី២ និងទី៣



## ប្រទេសម៉ាឡេស៊ី

ឯកឧត្តម អេដ្មម៉ាន់ ប៊ុន តៃ ស៊ូន H.E. Mr. Edmund Bon Tai Soon




## កម្រិតវប្បធម៌

- អនុបណ្ឌិតផ្នែកច្បាប់សិទ្ធិមនុស្សអន្តរជាតិ សាកលវិទ្យាល័យអកស្វើតOxford ចក្រភពអង់គ្លេស (អាហារូបករណ៍Chevening)
- បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ខូលេខនៃទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស (អាហារូបករណ៍ម៉ាឡេស៊ី)

## បទពិសោធន៍ការងារ

- ២០១៦៖ ប្រធានអង្គជំនុំជម្រះរឿងស៊ីវិល នៃគណៈមេធាវីAmerBONនៅទីក្រុងគូឡាឡាំពួ
- ២០១៤-២០១៦៖ ប្រធានអង្គជំនុំជម្រះនៃគណៈមេធាវីBON នៅទីក្រុងគូឡាឡាំពួរ
- ២០១២-២០១៤៖ ដៃគូក្រុមហ៊ុន Chooi និងCompany,មេធាវីនៅទីក្រុងគូឡាឡាំពួ
- ២០០២-២០១២៖ សហការីជាន់ខ្ពស់ ក្រុមហ៊ុនChooi និងCompany,មេធាវីនៅទីក្រុងគូឡាឡាំពួ
- ១៩៩៨-២០០២៖ សហការី ក្រុមហ៊ុនChooi និងCompany, មេធាវីនៅគូឡាឡាំពួ
- ២០១១៖ សហស្ថាបនិក មជ្ឈមណ្ឌលរដ្ឋធម្មនុញ្ញនិយម និងសិទ្ធិមនុស្ស
- ២០១០៖ សហនិពន្ធច្បាប់Halsbury នៃប្រទេសម៉ាឡេស៊ីស្តីពី សញ្ជាតិ, អន្តោប្រវេសន៍, សន្តិសុខជាតិ & ប៉ូលីស" (ភាគទី ២៧)។
- ២០១៦-២០១៧៖ ប្រធានគណៈកម្មាធិការនុវានុវត្តន៍ និងអនាគតនីតិសាស្ត្រ នៃក្រុមប្រឹក្សាវិជ្ជាជីវៈមេធាវី
- ២០០៩-២០១១៖ ប្រធានគណៈកម្មាធិការនីតិរដ្ឋធម្មនុញ្ញនៃក្រុមប្រឹក្សាវិជ្ជាជីវៈមេធាវី
- ២០០៧-២០០៩៖ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សនៃក្រុមប្រឹក្សាវិជ្ជាជីវៈមេធាវី
- ២០០៦-២០០៨៖ ប្រធានគណៈកម្មាធិការក្រុមមេធាវីជាតិវ័យក្មេងនៃក្រុមប្រឹក្សាវិជ្ជាជីវៈមេធាវី
- ២០០៦-២០១១; ២០១៦-២០១៧៖ សមាជិកដែលជ្រើសតាំងនៃក្រុមប្រឹក្សាវិជ្ជាជីវៈមេធាវី
- ២០០៦-២០០៨៖ សមាជិកលេខាធិការដ្ឋាន នៃ Suara Rakyat ប្រទេសម៉ាឡេស៊ី
- ២០០៦៖ សហស្ថាបនិកប្លុកច្បាប់blawg គេហទំព័រ www.loyarburok.com.
- ២០០៥-២០០៨៖ ទីប្រឹក្សាច្បាប់នៃគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន (UNHCR)

- ២០០៤-២០១៤៖ សមាជិក នៃសង្គមជាតិសិទ្ធិមនុស្ស (HAKAM)។
- ១៩៩៨-២០១៧៖ របាយការណ៍សិទ្ធិមនុស្ស និងរបាយការណ៍ផលប្រយោជន៍សាធារណៈច្រើនជាង៦០របាយការណ៍លើបណ្តាញផ្សព្វផ្សាយ និងកាសែត ហើយនិង ការបណ្តុះបណ្តាលលើស៩០០ម៉ោង និងកម្មវិធីបណ្តុះបណ្តាលសមត្ថភាពដែលធ្វើឡើងនៅក្នុងស្រុក និងតំបន់។
- ១៩៩៨៖ មេធាវីតុលាការកំពូលម៉ាឡាយ៉ា (វិជ្ជាជីវៈស្មារតីម៉ាឡាយ៉ា ខែមិថុនា ឆ្នាំ១៩៩៨។
- ១៩៩៧៖ មេធាវី នៅសមាគមកិត្តិយសលីនខុនអ៊ីន (វិជ្ជាជីវៈស្មារតីប្រទេសអង់គ្លេស & វែល នៅខែកញ្ញា ឆ្នាំ២០០៧)។



## ប្រទេសមីយ៉ាន់ម៉ា

ឯកឧត្តម អគ្គរដ្ឋទូត ឡា មីន H.E. Amb. Hla Myint



## កម្រិតវប្បធម៌

- អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈ នៃសាកលវិទ្យាល័យចនហបគីន សហរដ្ឋអាមេរិក
- បរិញ្ញាបត្រ ពីសាលវិទ្យាល័យយ៉ាងហ្គូន ប្រទេសមីយ៉ាន់ម៉ា

## បទពិសោធន៍ការងារ

- ២០១៥៖ តំណាងមីយ៉ាន់ម៉ាប្រចាំក្រុមការងារជាន់ខ្ពស់សហគមន៍អាស៊ានចក្ខុវិស័យក្រោយឆ្នាំ២០១៥
- ២០០៨-បច្ចុប្បន្ន៖ វេទិកាតំបន់អ្នកជំនាញ និងបុគ្គលជាន់ខ្ពស់ លើចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០១៥។
- ២០១១-២០១២៖ អ្នកជំនាញ និងឥស្សរជន នៃប្រទេសមីយ៉ាន់ម៉ាប្រចាំអាស៊ាន-អាមេរិច។
- ២០១១-២០១៤៖ សមាជិកគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិប្រទេសមីយ៉ាន់ម៉ា
- ២០០៨-២០១០៖ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពប្រចាំសហគមន៍កំមិនវេលនៃប្រទេសអូស្ត្រាលីនិងប្រទេសនូវែលសេឡង់។
- ២០០៦-២០០៨៖ អគ្គនាយកដ្ឋានអង្គការអន្តរជាតិ និងសេដ្ឋកិច្ចនៃក្រសួងការបរទេស
- អគ្គនាយកដ្ឋានបណ្តុះបណ្តាលស្រាវជ្រាវ និងភាសាបរទេសនៃក្រសួងការបរទេស
- ២០០៥-២០០៦៖ អគ្គនាយកដ្ឋានរងអង្គការអន្តរជាតិ និងសេដ្ឋកិច្ចនៃក្រសួងការបរទេស
- ២០០២-២០០៥៖ ទីប្រឹក្សារដ្ឋមន្ត្រីស្ថានទូតមីយ៉ាន់ប្រចាំទីក្រុងម៉ាប្រេតូរីយ៉ានៃអាហ្វ្រិកខាងត្បូង

- ១៩៩៨-២០០២៖ ប្រធាននាយកដ្ឋានអង្គការអន្តរជាតិ និងសេដ្ឋកិច្ចនៃក្រសួងការបរទេស
- ១៩៩២-១៩៩៨៖ លេខាទី១ នៃស្ថានអចិន្ត្រៃយ៍មីយ៉ាន់ម៉ាប្រចាំទីក្រុងញូយ៉ក សហរដ្ឋអាមេរិក
- ១៩៨៨-១៩៩២៖ ជំនួយការប្រធាននាយកដ្ឋាននៃក្រសួងការបរទេស
- ១៩៨៤-១៩៩២៖ លេខាទី៣ នៃស្ថានអចិន្ត្រៃយ៍មីយ៉ាន់ម៉ាប្រចាំទីក្រុងហ្សឺណែវ ប្រទេសស្វីស។
- ១៩៨០៖ ក្រសួងការបរទេស
- ១៩៧៤-១៩៨០៖ ក្រសួងកិច្ចការផ្ទៃក្នុង
- ១៩៧០-១៩៧៤៖ ក្រសួងអប់រំ



## ប្រទេសហ្វីលីពីន

ឯកឧត្តម លីអូរ ហឺរហើរ៉ា លឹម H.E. Mr. Leo M. Herrera-Lim
(តាំងពីខែធ្នូ ឆ្នាំ២០១៦)




## កម្រិតវប្បធម៌

- បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្វីលីពីន ប្រទេសហ្វីលីពីន
- បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនៃសាកលវិទ្យាល័យហ្វីលីពីន ប្រទេសហ្វីលីពីន

## បទពិសោធន៍ការងារ

- ខែឧសភា ឆ្នាំ២០១៧ - បច្ចុប្បន្ន៖ ជំនួយការលេខាធិការនៃការិយាល័យអនុរដ្ឋលេខាធិការទទួលបន្ទុកទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ នៃនាយកដ្ឋានការបរទេស។
- ខែកក្កដា ២០១៦ - ឧសភា ២០១៧៖ ជំនួយការពិសេសជាន់ខ្ពស់ នៃការិយាល័យអនុរដ្ឋលេខាធិការទទួលបន្ទុកទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ នៃនាយកដ្ឋានការបរទេស។
- ២០១៤-២០១៦៖ អគ្គកុងស៊ុលហ្វីលីពីនប្រចាំទីក្រុង ឡូសអាន់ជីឡេស រដ្ឋកាលីហ្វញ៉ា។
- ២០១០-២០១៤៖ អគ្គកុងស៊ុលហ្វីលីពីនប្រចាំទីក្រុងឈីកាកូ រដ្ឋអេលីណយ

- ២០០៨-២០១០៖ លេខាទី១ និងកុងស៊ុល **បន្ទាប់មករដ្ឋមន្ត្រី** និងអគ្គកុងស៊ុលហ្វីលីពីនប្រចាំទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស
- ១៩៩១-២០០០៖ ជំនួយការពិសេស នៃការិយាល័យអនុរដ្ឋលេខាធិការគោលនយោបាយការបរទេស
- ១៩៨៩-១៩៩១៖ ប្រធាននាយកដ្ឋានសហរដ្ឋអាមេរិច នៃការិយាល័យកិច្ចការច្បាប់ នៃនាយកដ្ឋានការបរទេស



## ប្រទេសសិង្ហបុរី

ឯកឧត្តម អគ្គរដ្ឋទូត បារ៊ី ដែសគី  H.E. Amb. Barry Desker




## កម្រិតវប្បធម៌

- អនុបណ្ឌិត នៃសាកលវិទ្យាល័យទីក្រុងឡុងដ៍ (អាហារូបករណ៍ Ford Foundation fellowship)
- បរិញ្ញាបត្រ នៃសាកលវិទ្យាល័យសិង្ហបុរី (អាហារូបករណ៍របស់ប្រធានាធិបតី)

## បទពិសោធន៍ការងារ

- សមាជិកនៃក្រុមប្រឹក្សាប្រធានាធិបតីដើម្បីសិទ្ធិជនជាតិភាគតិច
- ឯកអគ្គរដ្ឋទូតមិនតាំងទីនៃប្រទេសសិង្ហបុរីប្រចាំព្រះវិហារហូលីស៊ី និងប្រទេសអេស្ប៉ាញ
- អ្នកជំនាញ និងជាន់ខ្ពស់នៃប្រទេសសិង្ហបុរីប្រចាំវេទិកាតំបន់អាស៊ាន
- សមាជិកក្រុមប្រឹក្សាភិបាលអាហារូបករណ៍លើការផ្លាស់ប្តូរការសិក្សាលីក្វាន់យូ
- អនុប្រធានគណៈកម្មការត្រីភាគី
- សមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចដើម្បីអាស៊ាន និងអាស៊ីបូព៌ា។
- សមាជិកកិត្តិយសនៅ សាលាសិក្សអន្តរជាតិ S. Rajaratnam (RSIS)
- ២០០៧-២០១៤៖ព្រឹទ្ធបុរសនៃសាលាសិក្សាអន្តរជាតិ Rajaratnam នៃសាកលវិទ្យាល័យបច្ចេកវិទ្យា Nanyang (RSIS)
- ២០០០-២០១៤៖ នាយកវិទ្យាស្ថានការពារនិងសិក្សាយុទ្ធសាស្ត្រ។
- ១៩៩៤-២០០០៖ នាយកប្រតិបត្តិនៃក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍ពាណិជ្ជកម្ម
- ១៩៨៦-១៩៩៣៖ ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅប្រទេសឥណ្ឌូនេស៊ី

- ១៩៨៤-១៩៨៦៖ អនុរដ្ឋលេខាធិការ និងជាប្រធាននាយកដ្ឋានផ្នែកគោលនយោបាយ ផែនការនិងវិភាគនៃក្រសួងការបរទេស
- ១៩៨២-១០៨៤៖ អនុប្រធានតំណាងអចិន្ត្រៃយ៍ប្រចាំអង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក។



## ប្រទេសថៃ

ឯកឧត្តម បណ្ឌិត សិរី ណុនថាស៊ូន H.E. Dr. Seree Nonthasoon




## កម្រិតវប្បធម៌

- បណ្ឌិតផ្នែកទស្សនវិជ្ជានៃសាកលវិទ្យាល័យអកស្វើត ចក្រភពអង់គ្លេស
- សញ្ញាបត្រផ្នែកនីតិសាស្ត្រ និងComparative law នៃសាកលវិទ្យាល័យអកស្វើត Oxford ចក្រភពអង់គ្លេស
- បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ផ្នែកពាណិជ្ជកម្មអន្តរជាតិ នៃសាកលវិទ្យាល័យកូឡុមប៊ី សហរដ្ឋអាមេរិក
- សញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃគណៈមេធាវីប្រទេសថៃ
- បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យធម្មាសាធ ប្រទេសថៃ

## បទពិសោធន៍ការងារ

- តំណាងថៃប្រចាំអាយឆា (www.AICHR.or.th)
- នាយក និងសមាជិកគណៈកម្មាធិការសវនកម្ម នៃធនាគារអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម
- នាយក និងប្រធានសមាជិកគណៈកម្មាធិការសវនកម្ម នៃក្រុមហ៊ុនច្បាប់ខេប៊ីធី ខូអិលធីឌី
- នាយកក្រុមហ៊ុនសេវាកម្មកុំព្យូទ័រក្រុងថៃខូអិលធីឌី
- អនុប្រធានប្រតិបត្តិជាន់ខ្ពស់នៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍សហគ្រាសសាធារណៈ[www.IRDP.org]
- ២០០៤-បច្ចុប្បន្ន៖ ឧទ្ទេសាចារ្យពិសេសថ្នាក់មហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យធម្មសាធ
- ១៩៩៩-បច្ចុប្បន្ន៖ ឧទ្ទេសាចារ្យពិសេសថ្នាក់អនុបណ្ឌិតផ្នែកសិក្សាសិទ្ធិមនុស្ស (កម្មវិធីសិក្សាអន្តរជាតិ) នៃសាកលវិទ្យាល័យម៉ាហ៊ីដល
- ២០១១៖ សមាជិកក្រុមការងារពង្រាងលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន
- ២០០៣-២០១៣៖ ទីប្រឹក្សាច្បាប់ការិយាល័យគោលនយោបាយសហគ្រាសរដ្ឋ នៃក្រសួងហិរញ្ញវត្ថុ
- ១៩៩៥-២០០០៖ ទីប្រឹក្សាច្បាប់នៃការិយាល័យទីស្តីការរដ្ឋ នៃការិយាល័យនាយករដ្ឋមន្ត្រី

## ប្រទេសវៀតណាម

លោកជំទាវ អគ្គរដ្ឋទូត ង្វៀន ធី ញ៉ា H.E. Amb. Nguyen Thi Nha




### កម្រិតវប្បធម៌

- អនុបណ្ឌិតផ្នែកនីតិសាស្ត្រ និងការទូត នៃសាកលវិទ្យាល័យថាហ្វ សាកលវិទ្យាល័យម៉ាស្សាឈូសែត សហរដ្ឋអាមេរិក
- សញ្ញាបត្រTESOL នៃកង់បេរ៉ា ប្រទេសអូស្ត្រាលី
- បរិញ្ញាបត្រទំនាក់ទំនងអន្តរជាតិ សភាការទូតនៃប្រទេសវៀតណាម ទីក្រុងហាណូយ

### បទពិសោធន៍ការងារ

- ២០១៦-២១៨៖ ឯកអគ្គរដ្ឋទូត តំណាងវៀតណាមប្រចាំអាយធា
- ចាប់ពី២០១៣៖ ឯកអគ្គរដ្ឋទូត នៃក្រសួងការបរទេសវៀតណាម
- ២០១១-២០១៤៖ ប្រធានអគ្គនាយកដ្ឋាន នៃក្រសួងការបរទេស
- ២០១១-២០១៤៖ អគ្គកុងស៊ុលប្រទេសវៀតណាមប្រចាំហុងកុងនិងម៉ាកាវ - តំបន់ស្វ័យយ័តរដ្ឋបាលពិសេស ប្រទេសចិន
- ២០០៥-២០០៨៖ ទីប្រឹក្សារដ្ឋមន្ត្រី អនុប្រធានបេសកកម្ម ស្ថានទូតវៀតណាមប្រចាំចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង
- ១៩៩៥-១៩៩៩៖ លេខាទី១ នៃបេសកកម្មអចិន្ត្រៃយ៍ប្រទេសវៀតណាមប្រចាំអង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក
- ១៩៩០-១៩៩២៖ លេខាទី៣ នៃស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រទេសវៀតណាមប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀតនៅទីក្រុងសឺណែវ ប្រទេសស្វីស
- ១៩៩០-១៩៩២: លេខាទី៣ នៃស្ថានបេសកកម្មអចិន្ត្រៃយ៍វៀតណាមប្រចាំអង្គការសហប្រជាជាតិនិងអង្គការអន្តរជាតិដទៃទៀតនៅទីក្រុងសឺណែវ ប្រទេសស្វីស
- ១៩៨០-១៩៩០: មន្ត្រីនៃនាយកដ្ឋានកិច្ចការទូទៅនិងអង្គការអន្តរជាតិ។



**ប្រ៊ុយណេដារូសាឡឹម**

ឯកឧត្តម ប៉េហ៊ីន ដាតូ បណ្ឌិត អាវ៉ាង ហាជី អាម៉ាត់ ប៊ីន ហាជី ជូម៉ាត់






**ប្រទេសកម្ពុជា**

ឯកឧត្តម ស្រ៊ុន ជីវិទ្ធ






**ប្រទេសឥណ្ឌូនេស៊ី**

ឯកឧត្តម រ៉ាហ្វេនឌី ដេចាមីន






**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

ឯកឧត្តម ភូខង ស៊ីសូឡាត






**ប្រទេសម៉ាឡេស៊ី**

ឯកឧត្តម តាន ស្រី បណ្ឌិត មហាម៉ាត់ ស្យាហ្វី អាប់ឌុលឡា






## ប្រទេសមីយ៉ាន់ម៉ា

ឯកឧត្តម អគ្គរដ្ឋទូត យ៉ ទីន ស៊ី






## ប្រទេសហ្វីលីពីន

លោកជំទាវ អគ្គរដ្ឋទូត រ៉ូសារីអូ ហ្គុងស្សាឡេ ម៉ាណាឡូ



**ប្រទេសសិង្ហបុរី**
លោកជំទាវ អគ្គរដ្ឋទូត ចាន់ ហេង ឈី Chan Heng Chee




**ប្រទេសថៃ**
ឯកឧត្តម បណ្ឌិត សិរី ណុនថាស៊ូន



**ប្រទេសវៀតណាម**
លោកជំទាវ ឡឺ ជី ធូ




AIRCHR Representative 2009-2012 **តំណាងអាយុតា ២០០៩-២០១២**

**ប្រ៊ុយណេដារូសាឡឹម**

ឯកឧត្តម ប៉េហ៊ីន ដាតូ បណ្ឌិត អារ៉ាង ហាជី អាម៉ាត់ ប៊ីន ហាជី ជូម៉ាត់ (តាំងពីខែវិច្ឆិកា ឆ្នាំ២០១១)



**ប្រទេសកម្ពុជា**

ឯកឧត្តម ឱម យ៉ិនទៀង





**ប្រទេសឥណ្ឌូនេស៊ី**

ឯកឧត្តម រ៉ាហ្វេនឌី ដេចាមីន






**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

ឯកឧត្តម ប៊ូនគឹត សាំងសមសាក់





**ប្រទេសម៉ាឡេស៊ី**

ឯកឧត្តម តាន ស្រី បណ្ឌិត មហាម៉ាត់ ស្យាហ្វី អាប់ឌុលឡា






## ប្រទេសមីយ៉ាន់ម៉ា

ឯកឧត្តម អគ្គរដ្ឋទូត យ៉ ទីន ស្វី Kyaw Tint Swe





## ប្រទេសហ្វីលីពីន

លោកជំទាវ អគ្គរដ្ឋទូត រ៉ូសារីអូ ហ្គងស្សាឡេ ម៉ាណាឡូ





**ប្រទេសសិង្ហបុរី**

ឯកឧត្តម រ៉ិចឆាត មេឃនូស






**ប្រទេសថៃ**

លោកជំទាវ បណ្ឌិត ស្រីប្រាផា ពិតចាំរ៉ាមេស្រី





**ប្រទេសវៀតណាម**

ឯកឧត្តម អគ្គរដ្ឋទូត ង្វៀន ឌុយ ហុង


asean

## លក្ខន្តិកៈរបស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស

អនុលោមតាមមាត្រា១៤ នៃធម្មនុញ្ញអាស៊ាន គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស(អាយឆា) ត្រូវប្រតិបត្តិតាមលក្ខន្តិកៈដូចខាងក្រោមៈ

### ១. គោលបំណង

គោលបំណងរបស់អាយឆាគឺៈ

១.១. លើកកម្ពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់ប្រជាជនអាស៊ាន

១.២. ប្រកាន់ខ្ជាប់សិទ្ធិរបស់ប្រជាជនអាស៊ាន ក្នុងការរស់នៅក្នុងសន្តិភាព កិត្តិយស និងវិបុលភាព

១.៣. រួមចំណែកក្នុងសម្រេចឱ្យបាននូវគោលបំណងរបស់អាស៊ានដែលបានដាក់ចេញក្នុងធម្មនុញ្ញអាស៊ាន ដើម្បីលើកកម្ពស់ស្ថិរភាពនិងភាពសុខដុមក្នុងតំបន់ មិត្តភាព និងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមរដ្ឋសមាជិកអាស៊ាន ក៏ដូចជាសុខុមាលភាព ជីវភាព សង្គមកិច្ច និងការចូលរួមរបស់ប្រជាជនអាស៊ានក្នុងដំណើរការនៃការកសាងសហគមន៍អាស៊ាន

១.៤. លើកកម្ពស់សិទ្ធិមនុស្សក្នុងបរិបទតំបន់ ដោយត្រូវពិចារណាលើលក្ខណៈពិសេសនៅថ្នាក់ជាតិនិងថ្នាក់តំបន់ និងការគោរពគ្នាទៅវិញទៅមកចំពោះសាវតាប្រវត្តិសាស្ត្រ វប្បធម៌ និងសាសនាខុសគ្នា និងពិចារណាលើតុល្យភាពនៃសិទ្ធិនិងកាតព្វកិច្ច។

១.៥. ជំរុញកិច្ចសហប្រតិបត្តិការតំបន់ជាមួយនឹងទស្សនៈក្នុងការបំពេញបន្ថែមកិច្ចខិតខំថ្នាក់ជាតិនិងអន្តរជាតិលើការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និង

១.៦. ប្រកាន់ខ្ជាប់ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដូចមានចែងដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសទីក្រុងវីយែននិងកម្មវិធីសកម្មភាព និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលរដ្ឋសមាជិកអាស៊ានជាភាគី។

### ២. គោលការណ៍

អាយឆាត្រូវគោរពគោលការណ៍ដូចខាងក្រោមៈ

២.១. ការគោរពគោលការណ៍អាស៊ានដូចមានចែកក្នុងមាត្រា២នៃរដ្ឋធម្មនុញ្ញអាស៊ាន ជាពិសេសៈ

ក. ការគោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋសមាជិកអាស៊ានទាំងអស់

ខ. ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋសមាជិកអាស៊ាន

គ. ការគោរពសិទ្ធិរបស់រដ្ឋសមាជិកក្នុងការដឹកនាំអត្ថិភាពជាតិរបស់ខ្លួន ពីការជ្រៀតជ្រែក ការធ្វើវិទ្ធង្សនា និងការបង្ខិតបង្ខំខាងក្រៅ

ឃ. ការអនុលោមតាមនីតិរដ្ឋ អភិបាលកិច្ចល្អ គោលការណ៍ប្រជាធិបតេយ្យនិងរដ្ឋាភិបាលអាស្រ័យរដ្ឋធម្មនុញ្ញ

ង. ការគោរពសេរីភាពជាមូលដ្ឋាន ការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និងការលើកកម្ពស់យុត្តិធម៌សង្គម

ច. ការប្រកាន់ខ្ជាប់នូវធម្មនុញ្ញសហប្រជាជាតិនិងច្បាប់អន្តរជាតិ រួមបញ្ចូលទាំងច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវបានយល់ព្រមដោយរដ្ឋសមាជិកអាស៊ាន និង

ឆ. ការគោរពវប្បធម៌ ភាសា និងសាសនាផ្សេងគ្នារបស់ប្រជាជនអាស៊ាន ខណៈសង្កត់ធ្ងន់តម្លៃរួមរបស់ពួកគេក្នុងស្មារតីឯកភាពក្នុងពហុភាព។

២.២. គោរពគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ រួមបញ្ចូលភាពជាសកល ភាពមិនអាចកាត់ផ្តាច់បាន ការពឹងផ្អែកគ្នាទៅវិញទៅមក និងអន្តរទំនាក់ទំនងគ្នា នៃសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានទាំងអស់ ក៏ដូចជាភាពមិនលម្អៀង ភាព

ដាក់ស្តែង ភាពមិនត្រូវបានជ្រើសរើសជាមុន ភាពគ្មានការរើសអើង និងការជៀសវាងស្តង់ដារពីរ និងធ្វើនយោបាយនីយកម្ម

២.៣. ការទទួលស្គាល់ថាការទទួលខុសត្រូវចម្បងក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានគឺអាស្រ័យលើរដ្ឋសមាជិកនីមួយៗ

២.៤. ការអនុលោមតាមវិធីសាស្រ្តនិងកិច្ចសហប្រតិបត្តិការប្រកបដោយការស្ថាបនានិងគ្មានការប្រឈមមុខ ដើម្បីជំរុញការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និង

២.៥. ការអនុម័តវិធីសាស្រ្តនៃការវិវឌ្ឍ ដែលនឹងរួមចំណែកក្នុងការអភិវឌ្ឍបទដ្ឋាននិងស្តង់ដារសិទ្ធិមនុស្សក្នុងតំបន់អាស៊ាន។

## ៣. ស្ថាប័នអន្តររដ្ឋាភិបាលសម្រាប់ពិគ្រោះយោបល់

អាយចាគឺជាស្ថាប័នអន្តររដ្ឋាភិបាលនិងជាផ្នែកមួយនៃរចនាសម្ព័ន្ធចាត់តាំងអាស៊ាន។ អាយចាគឺជាស្ថាប័នសម្រាប់ពិគ្រោះយោបល់។

## ៤. អាណត្តិ និងមុខងារ

៤.១. បង្កើតបណ្តាយុទ្ធសាស្រ្តក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ដើម្បីបំពេញបន្ថែមការកសាងសហគមន៍អាស៊ាន

៤.២. បង្កើតសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ក្នុងគោលបំណងបង្កើតក្របខ័ណ្ឌមួយសម្រាប់កិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សតាមរយៈអនុសញ្ញាអាស៊ានផ្សេងៗ និងលិខិតុបករណ៍ដទៃទៀតពាក់ព័ន្ធនឹងសិទ្ធិមនុស្ស

៤.៣. ជំរុញការយល់ដឹងសិទ្ធិមនុស្សជាសាធារណៈក្នុងចំណោមប្រជាជនអាស៊ានតាមរយៈការអប់រំ ការស្រាវជ្រាវ និងការផ្សព្វផ្សាយព័ត៌មាន

៤.៤. លើកកម្ពស់ការកសាងសមត្ថភាពសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកាតព្វកិច្ចសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានអនុវត្តដោយរដ្ឋសមាជិកអាស៊ាន

៤.៥. លើកទឹកចិត្តរដ្ឋសមាជិកអាស៊ានក្នុងការពិចារណាចូលជាភាគី និងផ្តល់សច្ចាប័នដល់បណ្តាលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ

៤.៦. លើកកម្ពស់ការអនុវត្តឱ្យបានពេញលេញនូវលិខិតុបករណ៍អាស៊ានពាក់ព័ន្ធនឹងសិទ្ធិមនុស្ស

៤.៧. ផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសលើបញ្ហាសិទ្ធិមនុស្សដល់បណ្តាស្ថាប័នអាស៊ាន ប្រសិនបើមានសំណើ

៤.៨. ធ្វើទំនាក់ទំនងជាកិច្ចសន្ទនានិងពិគ្រោះយល់ជាមួយបណ្តាស្ថាប័នអាស៊ានផ្សេងៗ និងអង្គភាពពាក់ព័ន្ធនឹងអាស៊ានដែលរួមបញ្ចូលអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត ដូចមានចែងក្នុងជំពូក៥នៃធម្មនុញ្ញអាស៊ាន

៤.៩. ពិគ្រោះយោបល់ ប្រសិនបើសមស្រប ជាមួយស្ថាប័ននិងអង្គភាពថ្នាក់ជាតិ តំបន់ និងអន្តរជាតិដទៃទៀត ពាក់ព័ន្ធនឹងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស

៤.១០. ទទួលព័ត៌មានពីបណ្តារដ្ឋសមាជិកអាស៊ានលើការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស

៤.១១. បង្កើតយុទ្ធសាស្រ្ត និងជំហររួមលើបញ្ហាសិទ្ធិមនុស្សពាក់ព័ន្ធនឹងអត្ថប្រយោជន៍អាស៊ាន

៤.១២. រៀបចំការសិក្សាលើប្រធានបទសិទ្ធិមនុស្សក្នុងតំបន់អាស៊ាន

៤.១៣. ដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពរបស់ខ្លួនជូនកិច្ចប្រជុំរដ្ឋមន្រ្តីការបរទេសអាស៊ាន ឬរបាយការណ៍ផ្សេងៗ ប្រសិនបើចាំបាច់ និង

៤.១៤. អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអាចត្រូវបានប្រគល់ជូនដោយកិច្ចប្រជុំរដ្ឋមន្រ្តីការបរទេសអាស៊ាន។

## ៥. សមាសភាព

### សមាជិកភាព

៥.១. អាយឆាត្រូវមានសមាសភាពមកពរដ្ឋសមាជិកអាស៊ាន។

៥.២. រដ្ឋសមាជិកអាស៊ាននីមួយៗត្រូវតែងតាំងតំណាងមួយរូបប្រចាំអាយឆា ដែលត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋាភិបាលរបស់ខ្លួន។

### គុណវុឌ្ឍិ

៥.៣. នៅពេលដែលតែងតាំងតំណាងរបស់ប្រទេសប្រចាំអាយឆា រដ្ឋសមាជិកត្រូវពិចារណាលើសមភាពយេនឌ័រ សុចរិតភាព និងសមត្ថភាពក្នុងវិស័យសិទ្ធិមនុស្ស។

៥.៤. បណ្តារដ្ឋសមាជិកគួរពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងការតែងតាំងតំណាងរបស់ខ្លួនប្រចាំអាយឆា ប្រសិនបើតម្រូវដោយដំណើរការផ្ទៃក្នុងរបស់ប្រទេសរៀងៗខ្លួន។

### រយៈពេលកាន់តំណែង

៥.៥. តំណាងនីមួយៗមានអាណត្តិ៣ឆ្នាំ និងអាចត្រូវបានតែងតាំងបន្តម្តងទៀតសម្រាប់មួយអាណត្តិទៀត។

៥.៦. ទោះបីជាចែងក្នុងកថាខណ្ឌ៥.៥ក៏ដោយ រដ្ឋាភិបាលដែលតាំងតាំងអាចសម្រេចចិត្តដោយឆន្ទានុសិទ្ធ ក្នុងការផ្លាស់ប្តូរតំណាងរបស់ខ្លួន។

### ទំនួលខុសត្រូវ

៥.៧. អ្នកតំណាងនីមួយៗ ក្នុងអនុវត្តតួនាទីកាព្វកិច្ចរបស់ខ្លួន ត្រូវប្រតិបត្តិដោយគ្មានភាពលម្អៀង អនុលោមតាមធម្មនុញ្ញអាស៊ាននិងលក្ខន្តិកៈរបស់ខ្លួន។

៥.៨. អ្នកតំណាងត្រូវមានកាតព្វកិច្ចក្នុងការចូលរួមកិច្ចប្រជុំរបស់អាយឆា។ ប្រសិនបើអ្នកតំណាងមួយមិនមានលទ្ធភាពចូលរួមកិច្ចប្រជុំដោយកាលៈទេសៈលើកលែងណាមួយ រដ្ឋាភិបាលរបស់អ្នកតំណាងនោះត្រូវជូនដំណឹងផ្លូវការដល់ប្រធានរបស់អាយឆានូវការតែងតាំងអ្នកតំណាងបណ្តោះអាសន្នមួយដោយមានអាណត្តិពេញលេញក្នុងការតំណាងរដ្ឋសមាជិកនោះ។

### ប្រធានអាយឆា

៥.៩. ប្រធានអាយឆាត្រូវតែជាតំណាងរបស់រដ្ឋសមាជិកអាស៊ានដែលជាប្រធានអាស៊ាន

៥.១០. ប្រធានអាយឆាត្រូវអនុវត្តតួនាទីរបស់ខ្លួន ស្របតាមលក្ខន្តិកៈនេះ ដែលត្រូវរួមបញ្ចូលៈ

ក. ការដឹកនាំក្នុងការរៀបចំរបាយការណ៍របស់អាយឆា និងរាយការណ៍បណ្តារបាយការណ៍ជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន

ខ. ការសម្របសម្រួលជាមួយបណ្តាអ្នកតំណាងអាយឆានៅក្នុងកិច្ចប្រជុំរបស់អាយឆា និងជាមួយស្ថាប័នអាស៊ានពាក់ព័ន្ធ

គ. តំណាងអាយឆានៅព្រឹត្តិការណ៍ថ្នាក់តំបន់និងអន្តរជាតិពាក់ព័ន្ធនឹងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស ដោយទទួលបានការទុកចិត្តពីអាយឆា និង

ឃ. អនុវត្តមុខងារជាក់លាក់ផ្សេងៗ ដែលទទួលបានការទុកចិត្តពីអាយឆា ស្របតាមលក្ខន្តិកៈនេះ។

### អភ័យឯកសិទ្ធិនិងបុព្វសិទ្ធិ

៥.១១. អនុលោមតាមមាត្រា១៩នៃធម្មនុញ្ញអាស៊ាន បណ្តាអ្នកតំណាងចូលរួមក្នុងសកម្មភាពផ្លូវការផ្សេងៗរបស់អាយឆាត្រូវទទួលបានអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិសម្រាប់អនុវត្តមុខងាររបស់ខ្លួន ប្រសិនបើចាំបាច់

## ៦. បែបបទ

### ការធ្វើសេចក្តីសម្រេច

៦.១. ការធ្វើសេចក្តីសម្រេចក្នុងអាយឆាត្រូវផ្អែកលើកិច្ចពិគ្រោះយោបល់និងស្របតាមមាត្រា២០នៃធម្មនុញ្ញអាស៊ាន។

### ចំនួននៃកិច្ចប្រជុំ

៦.២. អាយឆាត្រូវប្រជុំសាមញ្ញ២ដងក្នុង១ឆ្នាំ។ កិច្ចប្រជុំនីមួយៗជាធម្មតាមិនត្រូវឱ្យលើសពី៥ថ្ងៃនោះទេ។

៦.៣. កិច្ចប្រជុំសាមញ្ញរបស់អាយឆាត្រូវប្រព្រឹត្តទៅឆ្លាស់គ្នានៅលេខាធិការដ្ឋានអាស៊ាន និងរដ្ឋសមាជិកដែលជាប្រធានអាស៊ាន។

៦.៤. អាយឆាអាចមានកិច្ចប្រជុំបន្ថែមនៅលេខាធិការដ្ឋានអាស៊ាន ឬនៅទីកន្លែងណាមួយដែលទទួលបានការយល់ព្រមពីបណ្តាអ្នកតំណាង ប្រសិនបើនិងពេលសមស្រប។

៦.៥. រដ្ឋមន្ត្រីការបរទេសអាស៊ានអាចបង្គាប់ឱ្យអាយឆារៀបចំកិច្ចប្រជុំ នៅពេលចាំបាច់។

### បែបបទនៃសេចក្តីរាយការណ៍

៦.៦. អាយឆាត្រូវដាក់របាយការណ៍ប្រចាំឆ្នាំនិងរបាយការណ៍សមស្របដទៃទៀតជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានសម្រាប់ពិនិត្យ។

### ព័ត៌មានជាសាធារណៈ

៦.៧. អាយឆាត្រូវផ្តល់ព័ត៌មានអំពីការងារនិងសកម្មភាពរបស់ខ្លួនដល់សាធារណៈជាប្រចាំ តាមរយៈទម្រង់ព័ត៌មានជាសាធារណៈសមស្រប ដែលធ្វើឡើងដោយអាយឆា។

### ទំនាក់ទំនងជាមួយបណ្តាស្ថាប័នសិទ្ធិមនុស្សផ្សេងៗក្នុងតំបន់នៅអាស៊ាន

៦.៨. អាយឆាគឺជាស្ថាប័នគ្រប់ដណ្តប់សិទ្ធិមនុស្សនៅក្នុងអាស៊ានដែលមានទំនួលខុសត្រូវជារួមលើការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនៅក្នុងអាស៊ាន។

៦.៩. អាយឆាត្រូវធ្វើការជាមួយបណ្តាស្ថាប័នអាស៊ានតាមវិស័យពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដើម្បីកំណត់ឱ្យបានឆាប់រហ័សនូវបែបបទសម្រាប់ទំនាក់ទំនងល្អបំផុតជាមួយនឹងអាយឆា។ ក្នុងន័យនេះ អាយឆាត្រូវពិគ្រោះពិភាក្សា សម្របសម្រួលនិងសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពទាំងនោះ ដើម្បីលើកកម្ពស់កិច្ចសហការរួមគ្នានិងភាពស៊ីចង្វាក់គ្នានៅក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សរបស់អាស៊ាន។

## ៧. តួនាទីរបស់អគ្គលេខាធិការនិងលេខាធិការដ្ឋានអាស៊ាន

៧.១. អគ្គលេខាធិការអាស៊ានអាចលើកឡើងបញ្ហាពាក់ព័ន្ធទៅកាន់អាយឆា ដែលស្របតាមមាត្រា១១.២ (a) និង (b) នៃធម្មនុញ្ញអាស៊ាន។ ជាមួយគ្នាផងដែរ អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងស្របគ្នាទៅរដ្ឋមន្ត្រីការបរទេសអាស៊ានពីបញ្ហាទាំងនេះ។

៧.២. លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់ការគាំទ្រចាំបាច់ផ្នែកលេខាធិការដល់អាយឆា ដើម្បីធានាការប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្របសម្រួលការគាំទ្ររបស់លេខាធិការដ្ឋានដល់អាយឆា រដ្ឋសមាជិកអាស៊ានអាចបញ្ជូនមន្ត្រីរបស់ខ្លួនទៅកាន់លេខាធិការដ្ឋានអាស៊ាន ដោយមានការយល់ព្រមពីអគ្គលេខាធិការអាស៊ាន។

## ៨. ផែនការការងារនិងមូលនិធិ

៨.១. អាយឆាត្រូវរៀបចំនិងដាក់ផែនការការងារនៃកម្មវិធីនិងសកម្មភាពជាមួយនឹងថវិកាដាក់លាក់សម្រាប់រយៈពេល៥ឆ្នាំ ដែលត្រូវបានយល់ព្រមពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន។

៨.២. អាយឆាក៏ត្រូវរៀបចំនិងដាក់ថវិកាប្រចាំឆ្នាំ ដើម្បីគាំទ្រកម្មវិធីនិងសកម្មភាពអាទិភាពខ្ពស់ ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ដោយផ្អែកលើលើអនុសាសន៍របស់គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន។

៨.៣. ថវិកាប្រចាំឆ្នាំត្រូវបានផ្តល់ដោយផ្អែកលើមូលដ្ឋានចែករំលែកស្មើភាពគ្នាដោយរដ្ឋសមាជិកអាស៊ាន។

៨.៤. អាយឆាក៏អាចទទួលធនធានពីបណ្តារដ្ឋសមាជិកអាស៊ានណាមួយសម្រាប់កម្មវិធីថវិកាបន្ថែមដាក់លាក់ពីផែនការការងារ។

៨.៥. អាយឆាក៏ត្រូវបង្កើតមូលនិធិទាយជ្ជទានមួយដែលមានការបរិច្ចាគដោយស្ម័គ្រចិត្តពីរដ្ឋសមាជិកអាស៊ាននិងប្រភពផ្សេងៗទៀត។

៨.៦. ការផ្តល់មូលនិធិនិងធនធានផ្សេងៗពីរដ្ឋមិនមែនសមាជិកអាស៊ានត្រូវតែសម្រាប់ការលើកកម្ពស់ ការកសាងសមត្ថភាព និងការអប់រំសិទ្ធិមនុស្សតែប៉ុណ្ណោះ។

៨.៧. មូលនិធិទាំងអស់ត្រូវបានប្រើដោយអាយឆាត្រូវបានគ្រប់គ្រងនិងផ្តល់ជូនស្របតាមបញ្ញត្តិហិរញ្ញវត្ថុទូទៅរបស់អាស៊ាន។

៨.៨. ការគាំទ្រផ្នែកលេខាធិការដ្ឋានសម្រាប់អាយឆាត្រូវផ្គត់ផ្គង់ដោយថវិកាប្រតិបត្តិការប្រចាំឆ្នាំរបស់លេខាធិការដ្ឋានអាស៊ាន។

## ៩. បញ្ញត្តិទូទៅ និងអវសានបញ្ញត្តិ

៩.១. លក្ខន្តិកៈនេះត្រូវចូលជាធរមាននៅពេលអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។

### វិសោធនកម្ម

៩.២. រដ្ឋសមាជិកនីមួយៗអាចដាក់សំណើផ្លូវការសម្រាប់ធ្វើវិសោធនកម្មនៃលក្ខន្តិកៈនេះ។

៩.៣. សំណើសម្រាប់វិសោធនកម្មត្រូវបានពិចារណាដោយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន ដោយមានកិច្ចពិគ្រោះយោបល់ជាមួយអាយឆា និងធ្វើបទបង្ហាញចំពោះកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានសម្រាប់ការអនុម័ត។

៩.៤. វិសោធនកម្មទាំងនេះត្រូវចូលជាធរមាននៅពេលទទួលបានការអនុម័តពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។

៩.៥. វិសោធនកម្មទាំងនេះមិនត្រូវប៉ះពាល់សិទ្ធិនិងកាតព្វកិច្ច ដែលកើតចេញឬផ្អែកលើលក្ខន្តិកៈនេះមុនពេលឬរហូតដល់ពេលវិសោធនកម្មទាំងនេះ។

### ការពិនិត្យឡើងវិញ

៩.៦. លក្ខន្តិកៈនេះត្រូវបានផ្តួចផ្តើមពិនិត្យឡើងវិញរយៈពេល៥ឆ្នាំបន្ទាប់ពីការចូលជាធរមាន។ ការពិនិត្យឡើងវិញនេះ និងការពិនិត្យឡើងវិញជាបន្តបន្ទាប់ត្រូវបានអនុវត្តដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ក្នុងទស្សនៈបន្តជំរុញការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ាន។

៩.៧. ក្នុងន័យនេះ អាយឆាត្រូវវាយតម្លៃការងាររបស់ខ្លួននិងដាក់អនុសាសន៍សម្រាប់ការពិចារណារបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីកិច្ចខិតខំនាពេលអនាគត ដែលអាចត្រូវបានអនុវត្តក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ាន ស្របតាមគោលការណ៍និងគោលបំណងរបស់ធម្មនុញ្ញអាស៊ាននិងលក្ខន្តិកៈនេះ។

ការបកស្រាយ

៩.៨. រាល់ការវែខ្ងគំនិតពាក់ព័ន្ធនឹងការបកស្រាយលក្ខន្តិកៈដែលមិនអាចដោះស្រាយបាន ត្រូវដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានសម្រេច។

**បញ្ជីសមាជិកនៃក្រុមការងារជាន់ខ្ពស់ស្តីពីស្ថាប័នសិទ្ធិមនុស្សអាស៊ានមួយ**

- **ប្រទេសប្រ៊ុយណេ ដារូសាឡឹម**
  **ឯកឧត្តម ដាតូ ស្សូហ្សហ្រ្វី អាបឌូល ហ្គាហ្វ៊រ**
  ក្រសួងការបរទេសនិងពាណិជ្ជកម្ម
- **ព្រះរាជាណាចក្រកម្ពុជា**
  **ឯកឧត្តម ឱម យិនទៀង**
  ទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
  ប្រធានគណៈកម្មការសិទ្ធិមនុស្សកម្ពុជា
- **ប្រទេសឥណ្ឌូនេស៊ី**
  **ឯកឧត្តម រ៉ាច្មាត់ ប៊ូឌីម៉េន**
  ប្រធាននាយកដ្ឋានសន្ធិសញ្ញានយោបាយ សន្តិសុខនិងទឹកដី
  នាយកដ្ឋានកិច្ចការបរទេស
- **សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**
  **ឯកឧត្តម ប៊ុនគឺត សាងសមសាក់**
  រដ្ឋលេខាធិការការបរទេស
  ក្រសួងការបរទេស
- **ម៉ាឡេស៊ី**
  **ឯកឧត្តម តាន់ ស្រ៊ី អាម៉ាត ហ្វូហ៊្សី អាបឌុល រ៉ាហ្សាក់**
  ឯកអគ្គរាជទូតវិសាមញ្ញ
  ក្រសួងការបរទេស
- **សាធារណៈរដ្ឋសហភាពមីយ៉ានម៉ា**
  **ឯកឧត្តម យូ ម្យ៉ាត កូ**
  លេខាធិការនៃក្រុមសិទ្ធិមនុស្សមីយ៉ានម៉ា
  អគ្គនាយកនៃនាយកដ្ឋានរដ្ឋបាលទូទៅ
  ក្រសួងមហាផ្ទៃ
- **ប្រទេសហ្វីលីពីន**
  **ឯកឧត្តមឯកអគ្គរដ្ឋទូត រ៉ូសារីអូ ជីម៉ាណាឡូ.**
  បេសកជនពិសេស
  ក្រសួងការបរទេស

- **ប្រទេសសិង្ហបុរី**
  **ឯកឧត្តម ប៊ីឡាហារី កាអ៊ូស៊ីកាន់**
  លេខាធិការអចិន្ត្រៃយ៍ទី២
  ក្រសួងការបរទេស
- **ព្រះរាជាណាចក្រថៃ**
  **ឯកឧត្តមឯកអគ្គរាជទូត ស៊ីហាសាក់ ផួងកេតកែវ**
  តំណាងអចិន្ត្រៃយ៍នៃប្រទេសថៃប្រចាំការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ
- **សាធារណៈរដ្ឋសង្គមនិយមវៀតណាម**
  **ឯកឧត្តម ផាម ង្វូង វិញ**
  ជំនួយការរដ្ឋមន្ត្រី
  ក្រសួងការបរទេស